Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

**ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍
និងកិច្ចសហប្រតិបត្តិការ (SDC)**

# កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេសស្វីស នៅកម្ពុជា

## យុទ្ធសាស្ត្រសហប្រតិបត្តិការតំបន់មេគង្គរបស់ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ (SDC) ២០១៣ - ២០១៧



## ទិដ្ឋភាពរួម
## ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ

ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ (ដែលហៅកាត់ជាភាសាអង់គ្លេសថា SDC) គឺជាទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសស្វីស នៅក្នុងក្របខ័ណ្ឌក្រសួងការបរទេស (ក្រសួងការបរទេសរបស់សហព័ន្ធ) របស់ប្រទេសស្វីស។ SDC ទទួលខុសត្រូវលើការងារអភិវឌ្ឍន៍ជារួម និងលើជំនួយមនុស្សធម៌ដែលផ្តល់ដោយសហព័ន្ធស្វីស។

SDC ផ្តល់ការគាំទ្រដល់ប្រទេសនានា ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជំនះបញ្ហានានា ដែលពាក់ព័ន្ធជាមួយនឹងភាពក្រីក្រ និងកិច្ចអភិវឌ្ឍន៍។ ជាពិសេស ទីភ្នាក់ងារនេះបង្កលក្ខណៈដល់ក្រុមដែលងាយរងគ្រោះ ឱ្យមានលទ្ធភាពក្នុងការទទួលបានសេវាអប់រំ និងសេវាថែទាំសុខភាព និងជួយដោះស្រាយបញ្ហាដែលពាក់ព័ន្ធជាមួយនឹងបរិស្ថាន។ សមភាពយេនឌ័រ និងអភិបាលកិច្ចល្អ គឺជាគោលការណ៍ដ៏សំខាន់ និងជាមគ្គុទេសក៍សម្រាប់ការបំពេញការងាររបស់ SDC។ SDC ប្តេជ្ញាដោះស្រាយបញ្ហាប្រឈមដែលកើតមានជាសកល ដូចជាការប្រែប្រួលអាកាសធាតុ និងកង្វះទឹកដែលកំពុងបង្កការលំបាកយ៉ាងធ្ងន់ធ្ងរដល់បណ្តាប្រទេសក្រីក្រ។ ទីភ្នាក់ងារនេះក៏ប្តេជ្ញាចិត្តខិតខំលើកកម្ពស់សកលភាពរូបនីយកម្មដែលបង្កលក្ខណៈដល់ការអភិវឌ្ឍន៍ផងដែរ។



# បុរេកថា

ប្រទេសស្វីស គឺជាអ្នកដែលផ្តល់ការគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយសមធម៌ និងចីរភាពក្នុងតំបន់មេគង្គជាយូរណាស់មកហើយ។ យុទ្ធសាស្ត្រថ្មីសម្រាប់ឆ្នាំ ២០១៣-២០១៧ របស់ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការ (SDC) តំបន់មេគង្គនេះគូសបញ្ជាក់សារជាថ្មីក្នុងការរក្សានូវការប្តេជ្ញាចិត្តនេះ។ ប្រទេសស្វីសនឹងបង្កើនវត្តមានក៏ដូចជា ទំហំថវិការបស់ខ្លួននៅក្នុងតំបន់មេគង្គនេះ តាមរយៈការបង្កើតគម្រោងថ្មីៗនៅក្នុងតំបន់នេះមានជាអាទិ៍នៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាមការបន្តកម្មវិធីប្រចាំប្រទេសរបស់ខ្លួននៅក្នុងប្រទេសឡាវ និងវៀតណាម និងការប្រកាសអនុវត្តនូវកម្មវិធីប្រចាំប្រទេសថ្មី នៅក្នុងប្រទេសកម្ពុជា។

យុទ្ធសាស្ត្ររបស់ប្រទេសស្វីសតំបន់មេគង្គនេះ ឆ្លើយតបទៅនឹងបញ្ហាប្រឈមធំៗដែលតំបន់នេះកំពុងប្រឈមដូចជា ការចាប់ផ្តើមដំណើរការនៃសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងដំណាច់ឆ្នាំ២០១៥។ ប្រទេសស្វីសផ្តល់ការគាំទ្រដល់ប្រទេសជាដៃគូរបស់ខ្លួននៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសទាំងនេះ ដើម្បីកាត់បន្ថយគម្លាតអភិវឌ្ឍន៍រវាងបណ្តាប្រទេសនានាដែល ជាសមាជិកអាស៊ាន។ ជារួមប្រទេសស្វីសមានបំណងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ គាំទ្រដល់សន្តិសុខស្បៀង អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងការបង្កើតការងារ និងការរកប្រាក់ចំណូល។ កម្មវិធីថ្នាក់តំបន់របស់ស្វីស មានបំណងពង្រឹងសមត្ថភាពរបស់តួអង្គរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលដើម្បីឱ្យពួកគេក្លាយជាដៃគូដោយស្មើភាពគ្នា និងប្រកបដោយភាពអង់អាចនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

នៅក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះប្រទេសកម្ពុជាបានសម្រេចនូវការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចសង្គមយ៉ាងធំធេងដោយបានប្រែក្លាយខ្លួនពីប្រទេសដែលហែកហួរដោយសង្គ្រាម ទៅជាប្រទេសដែលមានសុខសន្តិភាព និងស្ថិរភាពសង្គម។ ប្រទេសកម្ពុជាកំពុងស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ ក្នុងការឈានទៅសម្រេចតាមចំណុចដៅសំខាន់ៗដែលត្រូវបានដាក់ចេញនៅក្នុងគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាបើទោះបីជាផ្លូវទៅកាន់ប្រទេសចំណូលមធ្យម និងប្រកបដោយវិបុលភាពនៅវែងឆ្ងាយទៅមុខទៀតយ៉ាងណាក៏ដោយ។ បញ្ហាប្រឈមនានារួមមាន ៖ ការបង្កើនលទ្ធភាពទទួលបានសេវាសាធារណៈប្រកបដោយគុណភាព អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ សន្តិសុខស្បៀង និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពការអភិវឌ្ឍន៍ជំនាញ និងសមាហរណកម្មក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

អនុលោមតាមអាទិភាពជាតិនានាដែលត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៣-២០១៨) ដែលជាយុទ្ធសាស្ត្រថ្មីរបស់ប្រទេសកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរួម និងសមិទ្ធផលនានា ដែលសម្រេចបាននៅក្នុងតំបន់នេះ កម្មវិធីអភិវឌ្ឍន៍របស់ប្រទេសស្វីស នឹងផ្តោតលើវិស័យចំនួនបី។ សម្រាប់វិស័យអភិបាលកិច្ចមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋ SDC នឹងចូលរួមចំណែកលើកកម្ពស់ការផ្តល់សេវាសាធារណៈតាមរយៈការកសាងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងការលើកកម្ពស់សម្លេងរបស់ប្រជាពលរដ្ឋ។ សម្រាប់វិស័យកសិកម្ម និងសន្តិសុខស្បៀង SDC នឹងផ្តល់ការគាំទ្រឱ្យស្ត្រី និងបុរសដែលរស់នៅជនបទកែលំអការប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួន និងបង្កើនប្រាក់ចំណូលតាមរយៈការបង្កើនសមត្ថភាពផលិតកម្ម និងការគ្រប់គ្រងធនធានធម្មជាតិតាមសហគមន៍ប្រកបដោយចីរភាព។ សម្រាប់វិស័យការងារ និងអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ SDC នឹងគាំទ្រដល់ក្រុមជួបប្រទះការលំបាកបានបង្កើនជំនាញរបស់ខ្លួន ដើម្បីអាចរកការងារដែលផ្តល់នូវចំណូលច្រើនជាងមុន។ ទីភ្នាក់ងារនេះនឹងគាំទ្រដល់ការពង្រឹងប្រព័ន្ធអប់រំវិជ្ជាជីវៈ និងក្របខ័ណ្ឌបញ្ញត្តិកម្មលើការងារអប់រំវិជ្ជាជីវៈរបស់ប្រទេសនេះ។

យើងខ្ញុំរំពឹងថានឹងអនុវត្តយុទ្ធសាស្ត្រនេះ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល តួអង្គក្នុងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានាសំដៅសម្រេចឱ្យបាននូវលទ្ធផលនៃការអភិវឌ្ឍន៍ដែលអាចមើលឃើញជាក់ស្តែងជាពិសេសការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រនៅក្នុងប្រទេសកម្ពុជា។



Ruth Huber
នាយិកាថ្នាក់តំបន់ផ្នែកកិច្ចសហប្រតិបត្តិការ
ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការ
កម្មវិធីតំបន់មេគង្គ



Rahel Boesch
នាយិកាផ្នែកកិច្ចសហប្រតិបត្តិការ
ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ
ប្រទេសកម្ពុជា

# ពាក្យកាត់

| | |
|---|---|
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CEDAW** | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងស្ត្រីភេទ |
| **CHF** | រូបិយប័ណ្ណហ្វ្រង់របស់ស្វីស |
| **COOF** | ការិយាល័យសហប្រតិបត្តិការ |
| **CLMV** | ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម |
| **CSO** | អង្គការសង្គមស៊ីវិល |
| **EU** | សហភាពអឺរ៉ុប |
| **FAO** | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| **GBV** | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| **GIZ** | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| **INGO** | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| **IP3** | ផែនការអនុវត្ត ៣ ឆ្នាំនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **M&E** | ការពិនិត្យតាមដាន និងវាយតម្លៃ |
| **MAFF** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MDG** | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| **MERV** | ការពិនិត្យតាមដានលើការផ្លាស់ប្តូរដែលពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍន៍ |
| **MoLVT** | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **MoWA** | ក្រសួងកិច្ចការនារី |
| **MRS** | យុទ្ធសាស្ត្រសហប្រតិបត្តិការសម្រាប់តំបន់មេគង្គរបស់ប្រទេសស្វីស |
| **MTR** | ការពិនិត្យឡើងវិញពាក់កណ្តាលអណត្តិ |
| **NEA** | ទីភ្នាក់ងារជាតិការងារ និងមុខរបរ |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **NQF** | ក្របខ័ណ្ឌគុណវឌ្ឍិជាតិ |
| **NSDP** | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| **RIICE** | គម្រោងព័ត៌មានតាមរយៈការប្រើប្រាស់ប្រព័ន្ធរ៉ូម៉ូតសេនស៊ីង និងការធានារ៉ាប់រងដំណាំនៅតាមប្រទេសដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ (របស់ SDC) |
| **SAM** | គម្រោងសកម្មភាពខ្នាតតូចនៅតំបន់មេគង្គ (របស់ SDC) |
| **SCO** | ការិយាល័យសហប្រតិបត្តិការស្វីស |
| **SDC** | ទីភ្នាក់ងារស្វីស សម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ |
| **SIDA** | ទីភ្នាក់ងារស៊ុយអែត សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ |
| **SNA** | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **SNDD** | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **TVET** | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| **UNDP** | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| **UNICEF** | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| **UXO** | គ្រឿងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ |

# ១ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេសស្វីស ក្នុងតំបន់មេគង្គ

## អភិក្រមតំបន់ និងក្របខ័ណ្ឌរួម

យុទ្ធសាស្ត្រសហប្រតិបត្តិការតំបន់មេគង្គរបស់ប្រទេសស្វីស ២០១៣-២០១៧ ផ្តោតជាសំខាន់លើប្រទេសចំនួន ៤ គឺប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាមដែលស្ថិតនៅក្នុងតំបន់ភូមិសាស្ត្រតែមួយ ពោល គឺជាប្រទេសដែលស្ថិតនៅក្រោមក្របខ័ណ្ឌមហាអនុតំបន់មេគង្គ[១] និងអាស៊ានតែមួយ។ យុទ្ធសាស្ត្រប្រចាំតំបន់នេះក៏ធ្វើការពិចារណាផងដែរលើលក្ខណៈវប្បធម៌ នយោបាយ និងសេដ្ឋកិច្ចផ្សេងៗគ្នារបស់ប្រទេសទាំង ៤ ផងដែរ។ យុទ្ធសាស្ត្រនេះផ្តោតការយកចិត្តទុកដាក់នៅពីរកម្រិត៖

- ការផ្តោតការយកចិត្តទុកដាក់នៅថ្នាក់តំបន់ លើបញ្ហាប្រឈមផ្នែកការអភិវឌ្ឍន៍ដែលប្រទេស CLMV កំពុងជួបប្រទះដូចៗគ្នាជុំវិញការរៀបចំផែនការសមាហរណកម្មអាស៊ាន និងលើសក្តានុពលក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះរួមគ្នា ជាមួយនឹងការគាំទ្រពីស្ថាប័នឯកទេសក្នុងក្របខ័ណ្ឌតំបន់នេះ។

- ការផ្តោតការយកចិត្តទុកដាក់នៅកម្រិតប្រទេសលើបញ្ហាប្រឈមផ្នែកការអភិវឌ្ឍន៍ស្រដៀងគ្នានៅតាមប្រទេសនីមួយៗដោយធ្វើការពិចារណាលើបរិបទ និងក្របខ័ណ្ឌនៃការរៀបចំ ផែនការអភិវឌ្ឍន៍នៅតាមប្រទេសនីមួយៗក៏ដូចជាលើសក្តានុពលក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ តាមរយៈភាពជាដៃគូជាមួយនឹងដៃគូជាតិ និងអន្តរជាតិ។

យុទ្ធសាស្ត្រនេះដាក់ចេញនូវមូលដ្ឋានគ្រឹះ សម្រាប់ចូលរួមចំណែកធ្វើឱ្យមានសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ទាំងមូល និងជាពិសេសក្នុងការអភិវឌ្ឍន៍ប្រកបដោយសមធម៌ នៅក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា នៅក្នុងអន្តរកាលរបស់ប្រទេសនេះ ដើម្បីក្លាយខ្លួនជាប្រទេសដែលមានចំណូលមធ្យម។ ទីភ្នាក់ងារស្វីសដើម្បីការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការនឹងចូលរួមចំណែកនៅក្នុងការប្រមូលចងក្រងលទ្ធផលនៃការអភិវឌ្ឍន៍ដែលសម្រេចបាននៅក្នុងប្រទេសវៀតណាម ក្នុងពេលជាមួយគ្នាដែលទីភ្នាក់ងារនេះដកសកម្មភាពរបស់ខ្លួនបន្តិចម្តងៗនៅត្រឹមឆ្នាំ ២០១៦ ខណៈពេលដែលប្រទេសនេះបានក្លាយជាប្រទេសដែលមានចំណូលកម្រិតមធ្យមនៅក្នុងឆ្នាំ ២០១០។ ក្នុងពេលជាមួយគ្នារដ្ឋលេខាធិការដ្ឋានទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ស្វីសនឹងបង្កើនការគាំទ្រដល់ការធ្វើសមាហរណកម្មរបស់ប្រទេសវៀតណាមទៅក្នុងទីផ្សារ សកលលោក។

## គោលដៅរួមនៃយុទ្ធសាស្ត្រសហប្រតិបត្តិការតំបន់មេគង្គរបស់ប្រទេសស្វីស

ប្រទេសស្វីស ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ គាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយសមធម៌ និងនិរន្តភាព និងជម្រុញលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ ប្រទេសនេះជួយពង្រឹងតួអង្គរដ្ឋ និងមិនមែនរដ្ឋនៅប្រទេស CLMV នៅក្នុងការសម្រេចគោលដៅរបស់ខ្លួនដើម្បីក្លាយជាដៃគូស្មើភាពគ្នាប្រកបដោយភាពអង់អាចនៅក្នុងសហគមន៍អាស៊ាន ដែលនឹងបង្កើតឡើងនាពេលខាងមុខនេះ។

---

១ មហាអនុតំបន់ទន្លេមេគង្គ រួមមាន ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និងខេត្តយូណាន និងគ័ងស៊ីរបស់ប្រទេសចិន។

## វិស័យដែលផ្តោតការយកចិត្តទុកដាក់

វិស័យដែលកម្មវិធីនៅក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ ផ្តោតការយកចិត្តទុកដាក់សំខាន់រួមមានអភិបាលកិច្ចមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋ, កសិកម្ម និងសន្តិសុខស្បៀង ការងារ និងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របទៅតាមសារស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិឆ្នាំ ២០១៣-២០១៦ ថ្មីដែលបានថ្លែងទៅកាន់សភារបស់ប្រទេសស្វីស។ ការលើកកម្ពស់អភិបាលកិច្ចត្រូវបានចាត់ទុកថាជាកត្តាដែលសំខាន់ជាងគេបំផុត ដើម្បីសម្រេចឱ្យបាននូវកំណើនប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា និងប្រកបដោយចីរភាព នៅតាមបណ្តាប្រទេស CLMV ដែលផ្តល់លទ្ធភាពឱ្យប្រទេសទាំងនេះ អាចទាញប្រយោជន៍ពីសមាហរណកម្មសហគមន៍អាស៊ាន។ កសិកម្ម នៅតែបន្តជាមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋភាគច្រើននៅក្នុងមហាអនុតំបន់មេគង្គនេះដែលភាពក្រីក្រនៅតែមាននៅតាមតំបន់ជនបទភាគច្រើន និងមានក្នុងចំណោមក្រុមជនជាតិដើមភាគតិច។ ដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋក្រីក្រអាចទទួលបានប្រយោជន៍កាន់តែច្រើនជាងមុនពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងផ្តល់ឱកាសឱ្យប្រទេសទាំងនេះធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន ការងារនិងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានចាត់ទុកថាជាវិស័យសំខាន់ទី ៣ ដែលត្រូវផ្តោតការយកចិត្តទុកដាក់ នៅក្នុងប្រទេសកម្ពុជា និងឡាវ។ ការមានជំនាញខ្ពស់ជាងមុន នឹងផ្តល់លទ្ធភាពឱ្យយុវជនច្រើននាក់អាចចូលទៅក្នុងកម្លាំងពលកម្មជារៀងរាល់ឆ្នាំ ដើម្បីអាចរកការងារដែលផ្តល់កម្រៃកាន់តែច្រើនជាងមុន ហើយជំនាញកាន់តែខ្ពស់នឹងផ្តល់ឱកាសឱ្យពួកគេ អាចងើបចេញពីវិស័យកសិកម្មបាន។

ជារួមធនធានហិរញ្ញវត្ថុរបស់ SDC ចំនួន ១៥% នឹងត្រូវវិភាជន៍សម្រាប់កម្មវិធីនៅថ្នាក់តំបន់ហើយធនធានដែលនៅសល់ នឹងត្រូវបែងចែកសម្រាប់កម្មវិធីនៅថ្នាក់ប្រទេស។[២]

---

២ ឧបសម្ព័ន្ធទី ១ បង្ហាញដោយសង្ខេបអំពីយុទ្ធសាស្ត្រថ្នាក់តំបន់ និងបង្ហាញពីទំនាក់ទំនងរវាងគោលដៅនៃកម្មវិធី នៅថ្នាក់តំបន់ ជាមួយនឹងលទ្ធផលនៅកម្រិតប្រទេស។ ឧបសម្ព័ន្ធទី ៣ បង្ហាញព័ត៌មានលំអិតអំពីផែនការវិភាជន៍ ធនធានទៅតាមប្រទេស និងវិស័យ។

# ២ វិស័យគោលដៅនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសស្វីស ជាមួយនឹងប្រទេសកម្ពុជា ឆ្នាំ ២០១៣-២០១៧

វិស័យគោលដៅនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសស្វីសជាមួយនឹងប្រទេសកម្ពុជា ឆ្លើយតបចំពោះបញ្ហាប្រឈមសំខាន់ៗ ដែលជាឧបសគ្គរាំងស្ទះដល់ការអភិវឌ្ឍន៍របស់ប្រទេសនេះ ហើយមានទិសដៅស្របគ្នាយ៉ាងពេញលេញ ជាមួយនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣។ យុទ្ធសាស្ត្រ សហប្រតិបត្តិការសម្រាប់ប្រទេសកម្ពុជារបស់ SDC ត្រូវបានតាក់តែងឡើងដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងការជួបពិភាក្សាជាមួយនឹងទីភ្នាក់ងាររដ្ឋាភិបាលដៃគូផ្តល់ជំនួយ និងអង្គការសង្គមស៊ីវិល ដោយមានការសិក្សានិងការវិភាគជាច្រើនដែលធ្វើឡើងដោយអ្នកជំនាញកម្ពុជា និងអ្នកជំនាញអន្តរជាតិ។

SDC នឹងផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រ និងអ្នកគ្មានឱកាសទាំងស្ត្រីទាំងបុរសនៅក្នុងប្រទេសកម្ពុជា ជាពិសេសអ្នកដែលរស់នៅតាមតំបន់ជនបទ ដើម្បីឱ្យពួកគេអាចទទួលបានឱកាសសេដ្ឋកិច្ចប្រកបដោយសមធម៌លើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ និងចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ SDC ចូលរួមចំណែកកសាងឡើងវិញនូវការជឿជាក់ និងទំនុកចិត្ត ដើម្បីគាំទ្រដល់ការផ្សះផ្សាដែលជាធាតុផ្សំដ៏សំខាន់នៃស្ថិរភាពសន្តិភាព និងការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។

SDC នឹងផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋ, កសិកម្ម និងសន្តិសុខស្បៀង និងការងារ និងការអភិវឌ្ឍន៍ជំនាញ (ក្របខ័ណ្ឌ លទ្ធផលលំអិតសម្រាប់វិស័យនីមួយៗ ក្នុងចំណោមវិស័យទាំងបីមានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ២)។ កម្មវិធីសហប្រតិបត្តិការរបស់ប្រទេសស្វីសជាមួយប្រទេសកម្ពុជា គឺជាផ្នែកមួយនៃ យុទ្ធសាស្ត្រសហប្រតិបត្តិការប្រចាំតំបន់មេគង្គរបស់ប្រទេសស្វីស (២០១៣-២០១៨) ហើយក៏ផ្តោតទៅតាមសមិទ្ធផលដែល SDC សម្រេចបាននៅក្នុងប្រទេសឡាវ និងវៀតណាមផងដែរ (សូមមើលប្រអប់ទី ៣-៦)។

**ប្រអប់ទី ១ ៖ មេរៀនមួយចំនួន ដែល SDC ទទួលបាន នៅក្នុងតំបន់នេះ រួមមាន ៖**

- ការគាំទ្រដល់គ្រួសារក្រីក្រ ដែលរស់នៅតាមតំបន់ដាច់ស្រយាល មានឥទ្ធិពលយ៉ាងធំធេង ក្នុងការចូលរួមលើកកម្ពស់សន្តិសុខស្បៀងរបស់ពួកគេ និងលើការកាត់បន្ថយភាពក្រីក្រ។
- វិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម ដោយមានការចូលរួម ដែលត្រូវបានចងក្រងទុកជាឯកសារ និងបញ្ចូលទៅក្នុងប្រព័ន្ធអប់រំ/កម្មវិធីសិក្សារបស់រដ្ឋ ផ្តល់នូវប្រយោជន៍រយៈពេលវែងផ្នែកការអភិវឌ្ឍន៍ធនធានមនុស្ស។
- ការចូលរួមពិតប្រាកដ និងតម្លាភាពពេញលេញ គឺជាកត្តាសំខាន់ដែលនាំឱ្យមានការបំផុសចលនាប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋានប្រកបដោយជោគជ័យ។

## អភិបាលកិច្ចមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋ

ការពង្រឹងអភិបាលកិច្ចមូលដ្ឋាន និងការស្តារឡើងវិញនូវកោសិកាសង្គម ដែលត្រូវបានបំផ្លាញខ្ទេចខ្ទាំដោយសារតែសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា។ SDC នឹងចូលរួមចំណែកសម្រេចនូវការអភិវឌ្ឍន៍ប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នាដោយប្រើប្រាស់អភិក្រមដែលមានពីរផ្នែក៖ i) ពង្រឹងសមធម៌ ប្រសិទ្ធភាព និងឆ្លើយតបនៃសេវាសាធារណៈ និង ii) លើកកម្ពស់សម្លេងសិទ្ធិនិងការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន។ អភិក្រមនេះនឹង ជួយបំពេញបន្ថែមលើអន្តរាគមន៍របស់ SDC នៅក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជំនាញ។ ការកសាងនិងការគាំទ្រដល់វេទិកាផ្លោះប្តូរបទពិសោធន៍ ការសន្ទនា និងការកសាងការជឿទុកចិត្តគ្នានៅថ្នាក់ឃុំ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីព្យាបាលស្នាមរបួសផ្លូវចិត្ត និងឆ្លើយតបទៅនឹងភាពចាំបាច់ក្នុងការផ្សះផ្សា ក្រោយរបបប្រល័យពូជសាសន៍ និងសង្គ្រាមស៊ីវិលដែលអូសបន្លាយពេលដ៏យូរកន្លងមក។

**គោលដៅកម្មវិធី**

ការធ្វើឱ្យយន្តការអភិបាលកិច្ចមូលដ្ឋាន កាន់តែមានភាពល្អប្រសើរជាងមុនចូលរួមចំណែកលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍ប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា។

**លទ្ធផល**

ស្ត្រី និងបុរសដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះប្រើប្រាស់សេវាសាធារណៈ ដែលមានសមធម៌ និងឆ្លើយតបចំពោះតម្រូវការរបស់ពួកគេ (ដូចជា សេវាសុខភាព អប់រំ ទឹកស្អាត និងអនាម័យ)។

ប្រជាពលរដ្ឋជាពិសេសស្ត្រី និងក្រុមងាយរងគ្រោះ អាចលើកឡើងពីសេចក្តីត្រូវការរបស់ពួកគេ អនុវត្តសិទ្ធិរបស់ពួកគេ និងចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន។



## កសិកម្ម និងសន្តិសុខស្បៀង

ប្រជាពលរដ្ឋក្រីក្រនៅកម្ពុជាប្រមាណជា ៩០% រស់នៅតាមតំបន់ជនបទដែលករណី អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភមានកម្រិតខ្ពស់។ SDC មានបំណងចូលរួមចំណែកធ្វើឱ្យវិស័យកសិកម្មមានកំណើនប្រកបដោយសមធម៌ និងផ្តល់ប្រយោជន៍ដល់មនុស្សគ្រប់គ្នាដែលអាចធ្វើជាកម្លាំងចលករឱ្យមានការផ្លាស់ប្តូរជីវភាពកសិករក្រីក្រទាំងស្ត្រី ទាំងបុរស ដែលរស់នៅតំបន់ជនបទ។ កម្មវិធីនេះនឹងផ្តោតលើសកម្មភាពចំនួនពីរដែលមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទដូចជា i) ការបង្កើនភាពធន់នៃមុខរបរចិញ្ចឹមជីវិតរបស់កសិករតូចតាចរួមទាំង គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងជនជាតិដើមភាគតិចតាមរយៈការបង្កើនសមត្ថភាពផលិតកម្ម និងលទ្ធភាពទទួលបានទីផ្សារ និង ii) ការគាំទ្រដល់ស្ត្រី និងបុរសជាពិសេសសហគមន៍ដែលចិញ្ចឹមជីវិត អាស្រ័យដោយសារធនធានព្រៃឈើ និងនេសាទតាមរយៈការធានាឱ្យពួកគេអាចទទួលបានធនធានសហគមន៍ប្រកបដោយសមធម៌ និងទីផ្សារសម្រាប់អនុផលព្រៃឈើដែលពួកគេរកបាន។

### គោលដៅកម្មវិធី

លើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀងតាមតំបន់ជនបទជាពិសេសរបស់គ្រួសារ ដែលមានស្ត្រីជាមេគ្រួសារ។

### លទ្ធផល

កសិករខ្នាតតូច ទាំងស្ត្រី ទាំងបុរស (រាប់បញ្ចូលទាំងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងជនជាតិដើមភាគតិច) មានមុខរបរចិញ្ចឹមជីវិតដែលកាន់តែធន់ជាមួយនឹងវិបត្តិនានា។

ស្ត្រី និងបុរសជាពិសេសអ្នកមកពីសហគមន៍ជនជាតិដើមភាគតិចអាចបង្កើនផលិតកម្ម និងអាចទទួលបាន និងគ្រប់គ្រងចាត់ចែងធនធានក្នុងសហគមន៍របស់ពួកគេ (ដូចជាធនធានព្រៃឈើ និងធនធាននេសាទជាដើម) បានជាប់លាប់ប្រកបដោយសមធម៌។

### ប្រអប់ទី ២ ៖ សមិទ្ធផល ដែលសម្រេចបានដោយ SDC នៅក្នុងការលើកកម្ពស់អភិបាលកិច្ច មូលដ្ឋានក្នុងប្រទេសឡាវ

SDC បានផ្តល់ការគាំទ្រដល់ការរៀបចំរបៀបវារៈកំណែទម្រង់អភិបាលកិច្ច និងរដ្ឋបាលសាធារណៈ ដែលតម្រង់ទិសទៅរកការកែលំអ ការផ្តល់សេវាដល់ប្រជាពលរដ្ឋ។ តាមរយៈការផ្តល់កញ្ចប់ឥណទានប្រតិបត្តិការមន្ត្រីថ្នាក់ស្រុកជាង២៣០០ នាក់មកពីរដ្ឋបាលស្រុកចំនួន ៣៥ បានអភិវឌ្ឍសមត្ថភាពរបស់ខ្លួនក្នុងការអនុវត្តន៍នីតិវិធីរៀបចំផែនការ និងថវិកាតាមបែបចូលរួមសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចដោយប្រើប្រាស់គោលការណ៍ស្តីពីការចូលរួមតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ SDC បានចូលរួមចំណែកជាមួយនឹងរដ្ឋាភិបាលឡាវនៅក្នុងការបង្កើនការទទួលយកទស្សនទានស្តីពីការរៀបចំផែនការពីក្រោមឡើងលើការចូលរួមសកម្ម និងការជ្រើសរើសតំណាងតាមរយៈការបោះឆ្នោត។ ដោយសារតែមានការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន និងការផ្តល់ឥណទានសម្រាប់ផ្តល់សេវា មានអ្នកភូមិជាងកន្លះលាននាក់មកពី ២១ ស្រុកក្នុងចំណោម ៤៧ ស្រុកដែលក្រខ្សត់ជាងគេនៅក្នុងប្រទេសឡាវឥឡូវនេះកាន់តែមានលទ្ធភាពជាងមុនក្នុងការទទួលបានសេវាពីមណ្ឌលសុខភាព សាលារៀន និងទឹកស្អាត។

SDC បានឆ្លើយតបទៅនឹងបញ្ហាអភិបាលកិច្ចដីធ្លីដោយប្រើប្រាស់អភិក្រមនៃការគោរពសិទ្ធិមនុស្ស។ មានប្រជាពលរដ្ឋជាង ២០០០០ នាក់ (ដែលភាគច្រើនមកពីសហគមន៍ជនជាតិដើមភាគតិច) មកពីភូមិគោលដៅចំនួន ៤០ នៃខេត្តសាវ៉ាណ់ាន់ បានបង្កើនការយល់ដឹងរបស់ខ្លួនពីសិទ្ធិដែលពាក់ព័ន្ធនឹងដីធ្លីហើយឥឡូវនេះ មានសមត្ថភាពជាងមុនក្នុងការដោះស្រាយវិវាទនានាដែលពាក់ព័ន្ធជាមួយនឹងដីធ្លី។

### ប្រអប់ទី ៣ ៖ សមិទ្ធផល ដែលសម្រេចបានដោយ SDC នៅក្នុងការលើកកម្ពស់ជីវភាពរស់នៅតាម តំបន់ជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងប្រទេសឡាវ

ការរីកចម្រើនផ្នែកផលិតកម្ម និងការស្វែងរកទីផ្សារ ដោយមានការសម្របសម្រួលពី SDC បានផ្តល់លទ្ធភាពឱ្យកសិករអាចទទួលបានចំណីអាហារ និងចំណូលច្រើនជាងមុនសម្រាប់គ្រួសាររបស់ពួកគេ។ លទ្ធផលដែលសម្រេចបានមានដូចជា៖

- ប្រជាពលរដ្ឋ ១៧០០០ គ្រួសារជាពិសេសជនជាតិដើមភាគតិចកំពុងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដែលអាចផ្តល់លទ្ធភាពឱ្យពួកគេកាន់តែអាចពឹងអាស្រ័យបន្ថែមទៀតលើការបង្កបង្កើនផលលើដីស្រែចំការ និងលែងធ្វើការប្រមូលផលពីក្នុងព្រៃដូចមុនទៀត។
- សេវាផ្តល់ប្រឹក្សាបច្ចេកទេស ដែលមានគុណភាពប្រសើរជាងមុនបានធ្វើឱ្យមានការរីកចម្រើនយ៉ាងសំខាន់ផ្នែកចំណេះដឹងអាកប្បកិរិយា និងជំនាញរបស់មន្ត្រីក្រសួងកសិកម្ម និងរុក្ខាប្រមាញ់ ដែលនាំឱ្យការមានការផ្តល់ការគាំទ្រកាន់តែប្រសើរជាងមុនដល់កសិករ។ កសិករបានទទួលជំនាញកាន់តែប្រសើរជាងមុន ក្នុងការគ្រប់គ្រងប្រព័ន្ធកសិដ្ឋានដាំដុះរបស់ខ្លួន និងការចរចាជាមួយនឹងឈ្មួញដើម្បីឱ្យពួកគេកាន់តែអាចព្យាករដឹងមុនពីអ្វីដែលអាចកើតមានឡើងនៅក្នុងទំនាក់ទំនងរបស់ពួកគេ។
- ការអភិវឌ្ឍន៍សង្វាក់តម្លៃវិស័យកសិកម្ម នាំឱ្យមានការបង្កើនចំណូលរបស់គ្រួសារកសិករដែលចូលរួមក្នុងសកម្មភាពនេះ។ ឧទាហរណ៍ កសិករដែលដាំកាហ្វេបានបង្កើនចំណូលរបស់ខ្លួនដល់ទៅ ៣ ដងពី ០,៨០ ដុល្លារ/គីឡូ ដល់ ២,៤ ដុល្លារ/គីឡូ។
- ការដាក់ឱ្យអនុវត្តនូវវិធីសាស្ត្រ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធចម្រុះនៅក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីធ្វើឱ្យការប្រើប្រាស់ធនធានជីវចម្រុះសម្រាប់វិស័យកសិកម្មមានភាពល្អប្រសើរបំផុតការពារជីជាតិដី និងពង្រឹងសិទ្ធិប្រើប្រាស់ដីធ្លីរបស់កសិករ។ គំនិតផ្តួចផ្តើមទាំងនេះបានផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋ ៣០០០ គ្រួសារនៅក្នុង ៣៧ ភូមិ។

## មុខរបរនិងការងារ និងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ

ការងារដែលបង្កើតឡើងដោយកំណើនសេដ្ឋកិច្ចនៅក្នុងរយៈពេលថ្មីៗនេះ គឺមិនគ្រប់គ្រាន់ដើម្បីតាមឱ្យទាន់ចំនួនយុវជនស្វែងរកការងារធ្វើនៅក្នុងប្រទេសកម្ពុជា ឬក្រៅប្រទេសដែលចេះតែមានចំនួនច្រើនឡើងៗនោះទេ។ ប្រជាពលរដ្ឋត្រូវការជាបន្ទាន់នូវការអប់រំវិជ្ជាជីវៈ និងការអភិវឌ្ឍន៍ ជំនាញបន្ថែមទៀត ប្រសិនបើប្រទេសកម្ពុជាមានបំណងរក្សាភាពប្រកួតប្រជែង នៅក្នុងបរិបទ សមាហរណកម្មថ្នាក់តំបន់ និងឆ្លើយតបចំពោះភាពមិនស៊ីគ្នារវាងតម្រូវការទីផ្សារ និងកម្លាំងពលកម្មជំនាញដែលមាន។ ការការពារសិទ្ធិការងារក៏នឹងទទួលបានការផ្តោតការយកចិត្តទុកដាក់ផងដែរ។

កម្មវិធីរបស់ SDC នឹងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញរបស់បុរស និងស្ត្រីដែលរស់នៅតាមទីជនបទដើម្បីបង្កលក្ខណៈឱ្យពួកគេអាចទទួលបានប្រយោជន៍ពីឱកាសការងារដែលនឹងមាននាពេលខាងមុខ ជាពិសេសនៅក្នុងវិស័យទេសចរណ៍ដែលកំពុងតែមានការរីកចម្រើនខ្លាំង។ នៅកម្រិតគោលនយោបាយ SDCនឹងគាំទ្រដល់រដ្ឋាភិបាលលើ៖ i) ការអនុវត្តន៍ផែនការសកម្មភាពសម្រាប់គោលនយោបាយស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីធានាឱ្យមានភាពបន្សុីគ្នារវាងគោលនយោបាយអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងតម្រូវការរបស់វិស័យឯកជន និងការលើកកម្ពស់សិទ្ធិជាមូលដ្ឋាន និងii) ការដាក់បញ្ចូលសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

### គោលដៅកម្មវិធី

ស្ត្រី និងបុរសវ័យក្មេងដែលរស់នៅតាមទីជនបទទទួលបានជំនាញវិជ្ជាជីវៈ និងបំណិនជីវិតដែលផ្តល់លទ្ធភាពឱ្យពួកគេអាចបង្កើនប្រាក់ចំណូលរបស់ពួកគេបាន។

### លទ្ធផល

ស្ត្រី និងបុរសដែលចូលរួមនៅក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទទួលបានចំណូលកាន់តែច្រើនពីការងារសមរម្យដែលពួកគេទទួលបាន។

ពង្រឹងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ជាតិ ក្របខ័ណ្ឌប្បញ្ញត្តិកម្ម និងប្រព័ន្ធនៃការអនុវត្តន៍ ក្នុងគោលដៅឈានឆ្ពោះទៅរកសមាហរណកម្មអាស៊ាន។





## ការគាំទ្រដល់សុខភាពមាតា និងទារក

មន្ទីរពេទ្យកុមារគន្ធបុប្ផា ត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ ១៩៩២ ក្រោមគំនិតផ្តួចផ្តើមរបស់ វេជ្ជបណ្ឌិតជនជាតិស្វីស លោក Beat Richner។ មន្ទីរពេទ្យ នេះចូលរួមចំណែកយ៉ាងធំធេងក្នុងការលើកកម្ពស់សុខភាពកុមារ និងសេវាសុខភាពជាទូទៅនៅក្នុងប្រទេសកម្ពុជា។ SDC បានចាប់ផ្តើមផ្តល់ការគាំទ្រដល់មន្ទីរពេទ្យគន្ធបុប្ផាទាំង ៥ នៅក្នុងឆ្នាំ ១៩៩៤។ ចាប់តាំងពីពេលនោះមកមន្ទីរពេទ្យគន្ធបុប្ផាបានផ្តល់ការព្យាបាលដល់កុមារជាង ១ លាននាក់ដែលត្រូវការការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងកុមារជាង ១0 លាននាក់ជាអ្នកជំងឺក្រៅមន្ទីរពេទ្យ។

## ផ្នែកអន្តរវិស័យ

ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការ និងការបន្ស៊ុំឱ្យស្របតាមកិច្ចខិតខំប្រឹងប្រែងសំខាន់ៗ ដែលធ្វើឡើងដោយតួអង្គសង្គមស៊ីវិល និងរដ្ឋាភិបាលក្នុងការធានានូវកំណើនរយៈពេលវែងប្រកបដោយនិរន្តរភាព និងសម្រាប់ទាំងអស់គ្នា ប្រធានបទអន្តរវិស័យចំនួន ៤ នឹងត្រូវបញ្ជ្រាបចូលទៅក្នុងគ្រប់កម្មវិធី និងគម្រោងទាំងអស់ដូចជា ៖

សមភាពយេនឌ័រ ៖ ស្របពេលដែលរដ្ឋាភិបាល សង្គមស៊ីវិល និងទីភ្នាក់ងារអន្តរជាតិនានាបានខិតខំបំពេញការងារជាច្រើន ដើម្បីជម្រុញលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ស្ត្រីនៅតែបន្តជួបប្រទះនឹងបញ្ហាប្រឈមធំៗជាច្រើន ដែលបញ្ហាភាគច្រើនមានភាពពាក់ព័ន្ធ ជាមួយនឹងភាពក្រីក្រ និងផលប៉ះពាល់មកលើពួកគេ។ ក្រសួងកិច្ចការនារីបាន ផ្តល់អាទិភាពដល់ការពង្រឹងសមត្ថភាព ក្នុងការគាំទ្រដល់ការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់ រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW)

### ប្រអប់ទី ៤ ៖ សមិទ្ធផល ដែលសម្រេចបានដោយ SDC នៅក្នុងការគាំទ្រដល់ការប្រកបមុខរបរ ចិញ្ចឹមជីវិតក្នុងប្រទេសវៀតណាម

SDC បានជួយដល់កសិករក្រីក្រចំនួន ៨000នាក់ ស្រី ៩0% ដើម្បីបង្កើនប្រាក់ចំណូលរបស់ពួកគេប្រមាណជា ៧00 ដុល្លារ ក្នុងមួយឆ្នាំក្នុងមួយគ្រួសារ តាមរយៈការចិញ្ចឹមសត្វ និងការបង្កបង្កើនផលកសិកម្មខ្នាតតូច។ តាមរយៈគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្មខ្នាតតូចចំនួន ៣៤00 គម្រោង SDC បានជួយកែលំអជីវភាពរស់នៅដល់ប្រជាពលរដ្ឋចំនួន ៧៧000 គ្រួសារដែលក្នុងនោះមានប្រជាពលរដ្ឋក្រីក្រ ២0000 គ្រួសារ ហើយពួកគេពី ៣៥% ទៅ ៩0% ជាជនជាតិដើមភាគតិចអាស្រ័យទៅតាមទីតាំង។

ក្នុងនាមជាសហអ្នកផ្តល់ជំនួយ នៃមូលនិធិពហុជំនួយសម្រាប់ព្រៃឈើដែលគ្រប់គ្រងដោយរដ្ឋាភិបាលវៀតណាម SDC បានចូលរួមចំណែកក្នុងការការពារ និងអភិវឌ្ឍព្រៃឈើប្រកបដោយនិរន្តភាពដូចជា ៖

- ការរៀបចំលិខិតុបករណ៍គោលនយោបាយជាតិសំខាន់ៗដូចជា យុទ្ធសាស្រ្តអភិវឌ្ឍន៍ព្រៃឈើរបស់វៀតណាម ២00៦-២0២0 ដែលសរុបមានក្រឹត្យសេចក្តីសម្រេច និងសរាចរណ៍របស់រដ្ឋាភិបាលជាង ១0។
- ការគាំទ្រដល់ការអនុវត្តន៍កម្មវិធីចំនួន ៥ នៃយុទ្ធសាស្រ្តអភិវឌ្ឍន៍ព្រៃឈើរបស់វៀតណាម ដោយបានបង្កើនគំរបព្រៃឈើជាង ៥0000 ហិចតា និងផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋជាង ៤៥000 ហិចតា, កាត់បន្ថយភាពក្រីក្រតាមរយៈការបែងចែកដីព្រៃ ៤១000 ហិចតាដល់ប្រជាពលរដ្ឋ ២៣000 គ្រួសារដោយមានផ្តល់នូវលិខិតបញ្ជាក់ពីការប្រើប្រាស់ដីធ្លី។



និងការបញ្ជ្រាបសមភាពយេនឌ័រទៅក្នុង ក្របខ័ណ្ឌគោលនយោបាយទូទៅសម្រាប់ធ្វើជាវេទិកាដើម្បីសម្រេចឱ្យបាននូវសិទ្ធិមនុស្សរបស់ស្ត្រី។ ការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការកេងប្រវ័ញ្ចផ្លូវភេទ ដែលប្រព្រឹត្តមកលើស្ត្រី គឺជាអាទិភាពខ្ពស់ជាងគេមួយ។ ដូច្នេះហើយបានជាសមភាពយេនឌ័រត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផ្នែកទាំង ៣ ក្នុងសូចនាករនៅកម្រិតលទ្ធផល។ លទ្ធផលសំខាន់ៗជាក់លាក់នឹងត្រូវរៀបចំឡើងតាមរយៈសកម្មភាពជាវិជ្ជមានដែលមានទិសដៅស្របគ្នាជាមួយនឹងផែនការសកម្មភាពរបស់រដ្ឋាភិបាលស្តីពីការលើកកម្ពស់ភាពអង់អាចដល់ស្ត្រី។ រាល់ទិន្នន័យទាំងអស់របស់គម្រោងនឹងត្រូវបែងចែកតាមភេទ។

អភិបាលកិច្ចល្អនឹងត្រូវបានបញ្ជ្រាបដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ គោលការណ៍គណនេយ្យភាព និងតម្លាភាព ការចូលរួមការមិនរើសអើង ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ គោលការណ៍អភិបាលកិច្ចល្អទាំងនេះនឹងត្រូវអនុវត្តចេញពីទស្សនវិស័យដែលឈរលើមូលដ្ឋានសិទ្ធិមនុស្សក្នុងគោលបំណងពង្រឹងសមត្ថភាពរបស់អ្នកមានសិទ្ធិ ( right holders) និងអ្នកដែលត្រូវបំពេញភារកិច្ច ( duty bearers )។

ការគ្រប់គ្រងកម្មវិធីដែលគិតគូរពីជម្លោះ មានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងបរិបទក្រោយពេលមានជម្លោះ ដូចជាប្រទេសកម្ពុជាជាដើម។ ការគិតគូរពីជម្លោះ និងការទប់ស្កាត់អំពើហិង្សានឹងត្រូវបានបញ្ចូលជាសមាសភាគសំខាន់របស់គ្រប់កម្មវិធីទាំងអស់ហើយនឹងមានមូលដ្ឋានលើការវិភាគហានិភ័យពាក់ព័ន្ធនឹង“ការមិនបង្កគ្រោះថ្នាក់” “សិទ្ធិដើម្បីដឹងឮ” និងសក្តានុពលធ្វើឱ្យមានការផ្លាស់ប្តូរចំពោះវិវាទ និងដោះស្រាយការប៉ះទង្គិចផ្លូវចិត្ត។ ការលើកកម្ពស់ឱ្យមានវេទិកាពិគ្រោះយោបល់ និងផ្តោះប្តូរបទពិសោធន៍រវាងសហគមន៍ អង្គការសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋាមូលដ្ឋាន គឺជាមធ្យោបាយដ៏សំខាន់ ដើម្បីគាំទ្រដល់ការកសាងឡើងវិញនូវភាពជឿជាក់ និងទំនុកចិត្ត។

ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនឹងត្រូវដាក់បញ្ចូលជាប្រធានបទអន្តរវិស័យជាពិសេសនៅក្នុងការអនុវត្តន៍កម្មវិធីកសិកម្ម និងសន្តិសុខស្បៀង ដោយប្រើប្រាស់មធ្យោបាយដែលមានស្រាប់ដើម្បីធ្វើការវិភាគហានិភ័យនានា និងដាក់បញ្ចូលសកម្មភាពបង្ការ ឬកាត់បន្ថយផលប៉ះពាល់។

វប្បធម៌ ប្រៀបបាននឹងបេះដូងនៃការអភិវឌ្ឍន៍។ ដោយសារមានការទទួលស្គាល់បែបនេះ SDC លើកកម្ពស់ឱ្យមានការយល់ដឹងអំពីវប្បធម៌ និងលើកកម្ពស់វប្បធម៌ផ្សេងៗគ្នាក្នុងគោលបំណងធ្វើការបូកសរុបដំណើរការនៃការអភិវឌ្ឍន៍ដែលមាននៅតាមប្រទេសដែលខ្លួនកំពុងអនុវត្តសកម្មភាព។ ស្របទៅតាមគោលនយោបាយរួមរបស់ SDC ដើម្បីលើកកម្ពស់ការសម្តែងចេញនូវវប្បធម៌ចម្រុះនៅតាមប្រទេសជាដៃគូកម្មវិធីប្រចាំប្រទេសកម្ពុជារបស់ SDC នឹងវិភាជន៍ថវិកាប្រមាណជា ១% នៃថវិកាសរុបរបស់ខ្លួនចំពោះសកម្មភាពលើកកម្ពស់វប្បធម៌។

# ៣ ការគ្រប់គ្រង និងការពិនិត្យតាមដានកម្មវិធី

## ទម្រង់ការនៃហិរញ្ញប្បទានសហប្រតិបត្តិការ

នៅក្នុងការរៀបចំ និងអនុវត្តគម្រោង និងកម្មវិធីនានា SDCនឹងអនុវត្តតាមគោលការណ៍ ដូចខាងក្រោម ៖

- ការប្រើប្រាស់ទម្រង់ការអនុវត្តន៍ចម្រុះ (គម្រោង "ដែលត្រូវរៀបចំដោយខ្លួនឯង" ដូចដែលតម្រូវនៅក្នុងច្បាប់, ការចូលរួមផ្តល់ហិរញ្ញប្បទានជាមួយនឹងទីភ្នាក់ងារទ្វេភាគី, ការចូលរួមបដិភាគក្នុងកម្មវិធីនានារបស់រដ្ឋាភិបាលទីភ្នាក់ងារពហុភាគីអង្គការមិនមែនរដ្ឋាភិបាល។ល។) នឹងផ្តល់លទ្ធភាពឱ្យ SDC អាចមានភាពបត់បែនក្នុងការឆ្លើយតបទៅនឹងឱកាស ឬ ឧបសគ្គនានានៅក្នុងបរិបទនយោបាយដែលកំពុងមាន និងដើម្បីផ្លាស់ប្តូរការផ្តោតគោលដៅនៃកម្មវិធីរបស់ខ្លួនទៅលើដៃគូ និងសកម្មភាពទាំងឡាយដែលនឹងផ្តល់នូវលទ្ធផលផ្នែកការអភិវឌ្ឍន៍ល្អបំផុតសម្រាប់ក្រុមគោលដៅដែលបានកំណត់។
- បន្ថែមពីលើការផ្តល់ការគាំទ្រដល់កំណែទម្រង់នៅថ្នាក់ជាតិ SDC នឹងផ្តោតការយកចិត្តទុកដាក់លើខេត្តមួយចំនួនដែលប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះមិនបានទទួលសេវាគ្រប់គ្រាន់ ឬនៅតាមតំបន់ ដែលមានសក្តានុពលក្នុងការផ្គួបកម្លាំងជាមួយនឹងដៃគូ ផ្តល់ជំនួយដទៃទៀត។ SDC នឹងប្រើប្រាស់អភិក្រមតាមតំបន់ដែលបង្កលក្ខណៈអាចដោះស្រាយបញ្ហាស្មុគស្មាញដែលមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមកបានគ្រប់ជ្រុងជ្រោយ។ ខេត្តដែលគ្រោងនឹងជ្រើសរើសធ្វើជាខេត្តគោលដៅរួមមានខេត្តនៅតាមតំបន់ខ្ពង់រាប និងតំបន់ភ្នំ (ដូចជាខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ) និងតំបន់មួយចំនួនដែលស្ថិតនៅតាមតំបន់វាលទំនាបទន្លេមេគង្គ (ដូចជាខេត្តស្ទឹងត្រែង និងក្រចេះជាដើម)។ សូមមើលឧបសម្ព័ន្ធទី ៤ អំពីផែនទីរបស់ប្រទេសកម្ពុជា។
- កម្មវិធីប្រចាំប្រទេសកម្ពុជារបស់ប្រទេសស្វីសនឹងសហការឱ្យបានជិតស្និទ និងផ្គួបកម្លាំងគ្នាជាមួយនឹងកម្មវិធីនៅថ្នាក់តំបន់ដែលរៀបចំ និងអនុវត្តដោយ SDC នៅក្នុងបរិបទនៃកម្មវិធីប្រចាំតំបន់មេគង្គរបស់ប្រទេសស្វីសដូចជា កម្មវិធីអភិបាលកិច្ចដីធ្លីព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងទឹកតាមបែបសមាហរណកម្មឆ្លងដែន។
- កម្មវិធីសកលរបស់ SDC ផ្នែកសន្តិសុខស្បៀង ការប្រែប្រួលអាកាសធាតុគំនិតផ្តួចផ្តើមទឹកទេសន្តរប្រវេសន៍ និងសុខភាពក្រោមការសម្របសម្រួលពីការិយាល័យកណ្តាលរបស់ SDC កាន់តែបង្កើនការគ្របដណ្តប់ខ្លាំងឡើងៗនៅតំបន់មេគង្គនេះ។ គម្រោងទាំងនេះបង្ក លក្ខណៈឱ្យមានការសហការយ៉ាងជិតស្និទ្ធ និងការផ្គួបកម្លាំងជាមួយនឹងគម្រោងនានានៅថ្នាក់តំបន់ និងនៅកម្រិតប្រទេស។ មានកម្មវិធីចំនួន ២ គឺកម្មវិធីព័ត៌មានតាមរយៈការប្រើប្រាស់ប្រព័ន្ធរ៉ូម៉ូតសេនស៊ីង និងការធានារ៉ាប់រងដំណាំនៅតាមប្រទេសដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ (RIICE)

៣ http://www.riice.org





និងកម្មវិធីផ្ដល់ការគាំទ្រ ដល់បណ្ដាញព្រៃឈើសង្គមថ្នាក់តំបន់ក្រោមក្របខ័ណ្ឌអាស៊ាន។ SDC នឹងជម្រុញឱ្យមានការបង្កើតច្រកប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ក៏ដូចជាធ្វើការពង្រឹងបន្ថែមទៀត នូវការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកជាមួយនឹងកិច្ចសហប្រតិបត្តិការកម្រិតសកលរបស់ SDC។

- អង្គការមិនមែនរដ្ឋាភិបាលស្វីសជាច្រើនបាន និងកំពុងអនុវត្តសកម្មភាពជាច្រើនឆ្នាំមកហើយនៅក្នុងប្រទេសកម្ពុជា។ SDC នឹងធ្វើការពិនិត្យតាមដានលទ្ធផលដែលសម្រេចបានដោយអង្គការមិនមែនរដ្ឋាភិបាលស្វីសតាមរយៈគម្រោងដែលទទួលបានថវិកាពី SDC ក៏ដូចជាធ្វើការពង្រឹងការផ្លាស់ប្ដូរបទពិសោធន៍ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលស្វីសនានាដែលកំពុងអនុវត្តសកម្មភាពនៅក្នុងតំបន់នេះ។

## ភាពជាដៃគូ

រាល់គម្រោងទាំងអស់នឹងត្រូវអនុវត្តតាមរយៈ ឬក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយនឹងទីភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និង/ឬអង្គការសង្គមស៊ីវិល។

- SDC នឹងចូលរួមយ៉ាងសកម្មក្នុងកិច្ចពិគ្រោះយោបល់គោលនយោបាយ និងការសម្របសម្រួលជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាក្នុងគ្រប់វិស័យទាំងអស់ដែលទីភ្នាក់ងារនេះកំពុងអនុវត្តសកម្មភាព។ លើសពីនេះ SDC នឹងចូលរួមនៅក្នុងការសម្របសម្រួលរវាងរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយផងដែរ។
- ប្រទេសស្វីសតាមរយៈ SDC បានចូលរួមនៅក្នុងយុទ្ធសាស្ត្រសហប្រតិបត្តិការអភិវឌ្ឍន៍ អឺរ៉ុបសម្រាប់ប្រទេសកម្ពុជា ២០១៤-២០១៨ ហើយនឹងចូលរួមចំណែកនៅក្នុងការអនុវត្តន៍យុទ្ធសាស្ត្រនេះ។
- SDC នឹងស្វែងរកឱកាស ដើម្បីចូលរួមផ្ដល់ហិរញ្ញប្បទានដល់កម្មវិធីពហុភាគី ឬកិច្ចសហប្រតិបត្តិការដែលខ្លួនទទួលបានប្រតិភូកម្មឱ្យចូលរួម ជាមួយនឹងទីភ្នាក់ងារទ្វេភាគីដ៏ទៃទៀត។ ដើម្បីប្រសិទ្ធភាព SDC នឹងរក្សាចំនួនគម្រោងឱ្យនៅតិចបំផុតជាមួយនឹងថវិកាតិចជាង ១ លាន CHF ក្នុងមួយឆ្នាំ។
- SDC នឹងព្យាយាមឱ្យមានការចូលរួមពីស្ថាប័នដៃគូចម្រុះ និងការប្រើប្រាស់ទម្រង់ការ សម្រាប់អនុវត្តសកម្មភាពចម្រុះក្នុងស្មារតីនៃគោលការណ៍ស្ដីពីប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ដែលត្រូវបានឯកភាពនៅទីក្រុងប៊ូសាន។ ការសម្របសម្រួលជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋាភិបាលជាដៃគូ គឺជាកិច្ចការដ៏សំខាន់។ បើទោះបីជាកម្មវិធីរបស់ SDC ត្រូវបានបន្សុីជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏ដោយសក្ដានុពលក្នុងការផ្ដល់ថវិកាដោយផ្ទាល់មានកម្រិតទាប។

## ការពិនិត្យតាមដាន និងវាយតម្លៃ

ឧបករណ៍សំខាន់ជាងគេដើម្បីដឹងពីលទ្ធផលការងារនានា គឺរបាយការណ៍វឌ្ឍនភាពដែលផ្ដល់ដោយដៃគូ កិច្ចពិគ្រោះយោបល់ជាមួយដៃគូ ការចុះទស្សនកិច្ចដល់មូលដ្ឋាន និងការវាយតម្លៃគម្រោង។ សិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំនឹងរៀបចំឡើងរួមជាមួយនឹងដៃគូដែលអនុវត្តកម្មវិធីនៅក្នុងវិស័យនីមួយៗ។

ដើម្បីធ្វើការពិនិត្យតាមដានលទ្ធផលនៃការអភិវឌ្ឍនីវិស័យនីមួយៗ SDC នឹងប្រើប្រាស់ សូចនាករដែលរៀបចំឡើងក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការប្រចាំតំបន់មេគង្គ របស់ប្រទេសស្វីស។ ប្រព័ន្ធពិនិត្យតាមដាននេះនឹងត្រូវធ្វើសុខដុមនីយកម្ម ជាមួយនឹងក្របខ័ណ្ឌ លទ្ធផលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ របាយការណ៍ពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាប្រភពព័ត៌មានដ៏សំខាន់។

ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិលើការអនុវត្តន៍កម្មវិធីប្រចាំប្រទេសកម្ពុជានឹងត្រូវធ្វើឡើងនៅក្នុងឆ្នាំ ២០១៥ រួមគ្នាជាមួយនឹងការពិនិត្យឡើងវិញលើយុទ្ធសាស្ត្រសហប្រតិបត្តិការប្រចាំតំបន់មេគង្គរបស់ប្រទេសស្វីស។ ការរាយការណ៍ពីការបំពេញការងារ និងលទ្ធផលដែលសម្រេចបាននឹងធ្វើទៅតាមនីតិវិធីស្តង់ដាររបស់ SDC ពោលគឺរបាយការណ៍ស្ដីពីភាពអនុលោមរបាយការណ៍ស្ដីពីការគ្រប់គ្រងការិយាល័យ និងរបាយការណ៍ប្រចាំឆ្នាំនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ICS) ប្រចាំឆ្នាំ។

## ការគ្រប់គ្រងហានិភ័យ

ការពិនិត្យតាមដាន និងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងហានិភ័យដៃគូរបស់កម្មវិធីនឹងត្រូវធ្វើឡើងដោយប្រើប្រាស់ឧបករណ៍គម្រោងដែលមានស្រាប់។ ហានិភ័យសំខាន់ៗនៃកម្មវិធីសម្រាប់វិស័យនីមួយៗត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌលទ្ធផល។ ការពិនិត្យតាមដានហានិភ័យពាក់ព័ន្ធជាមួយនឹងការសន្មតពីបរិបទត្រូវធ្វើឡើងដោយប្រើប្រាស់ឧបករណ៍ MERV របស់ SDC (ដែលជាឧបករណ៍សម្រាប់ធ្វើការពិនិត្យតាមដានការផ្លាស់ប្ដូរនៅក្នុងបរិបទប្រតិបត្តិការ)។ ការពិនិត្យតាមដានហានិភ័យ ពាក់ព័ន្ធជាមួយនឹងសម្មតិកម្មអំពីផលប៉ះពាល់របស់គម្រោងនឹងត្រូវធ្វើឡើង តាមរយៈការសិក្សាពីផលប៉ះពាល់។ វិធានការកាត់បន្ថយហានិភ័យនឹងត្រូវអនុម័តតាមរយៈរបាយការណ៍ប្រចាំឆ្នាំនៅក្នុងករណីហានិភ័យពាក់ព័ន្ធជាមួយនឹងបរិបទ និងតាមរយៈការឆ្លើយតបរបស់អ្នកគ្រប់គ្រងចំពោះលទ្ធផលនៃការពិនិត្យឡើងវិញលើគម្រោងនៅពេលដែលហានិភ័យមានទំនាក់ទំនងជាមួយនឹងតក្កភាពនៃការចូលរួមចំណែករបស់គម្រោងនានា។ នៅក្នុងប្រទេសកម្ពុជា ការគ្រប់គ្រងកម្មវិធីដែលគិតគូរពីជម្លោះត្រូវបានអនុវត្តដើម្បីគ្រប់គ្រងហានិភ័យដែលកើតចេញពីភាពតានតឹងក្នុងសង្គម។

# ឧបសម្ព័ន្ធ

១. សេចក្តីអធិប្បាយដោយសង្ខេបអំពីយុទ្ធសាស្ត្រសហប្រតិបត្តិការតំបន់មេគង្គ ២០១៣-២០១៧
២. ក្របខ័ណ្ឌលទ្ធផលរបស់ប្រទេសកម្ពុជា
៣. ការរៀបចំផែនការវិភាជន៍ថវិកា បែងចែកតាមប្រទេស និងវិស័យ
៤. ផែនទីប្រទេសកម្ពុជា



# ឧបសម្ព័ន្ធទី ១ ៖ សេចក្តីអធិប្បាយដោយសង្ខេបអំពីយុទ្ធសាស្ត្រសហប្រតិបត្តិការតំបន់មេគង្គ ២០១៣-២០១៧

**គោលដៅកម្មវិធី**

ប្រទេសស្វីសចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ គាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយសមធម៌ និងចីរភាព និងលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ ប្រទេសស្វីសនឹងពង្រឹងរដ្ឋាភិបាលនៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម និងតួអង្គមិនមែនរដ្ឋាភិបាល ដើម្បីឱ្យពួកគេក្លាយជាដៃគូស្មើភាពគ្នា និងប្រកបដោយភាពអង់អាចនៅក្នុងសហគមន៍អាស៊ានដែលនឹងចេញជារូបរាងនាពេលខាងមុខនេះ។

**ប្រធានបទអន្តរវិស័យ**

- សមភាពយេនឌ័រ
- អភិបាលកិច្ចល្អ (គណនេយ្យភាព ការចូលរួម ការមិនរើសអើង ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ តម្លាភាព)
- ការបន្ស៊ាំ និងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- ការគ្រប់គ្រងកម្មវិធីដោយគិតគូរពីជម្លោះដែលធ្លាប់កើតមាន

| លទ្ធផលនៃកម្មវិធីប្រចាំតំបន់មេគង្គ | អភិបាលកិច្ចមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋ | កសិកម្ម និងសន្តិសុខស្បៀង | ការងារ និងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ |
|---|---|---|---|
| លទ្ធផលកម្មវិធីនៅថ្នាក់តំបន់ | ១.១ តួអង្គនានាដែលអនុវត្តការងារអភិវឌ្ឍន៍នៅតាមប្រទេសក្នុងតំបន់មេគង្គ ទាញប្រយោជន៍ពីឱកាសនៃកំណើនសេដ្ឋកិច្ចតាមរយៈការកែលំអការភ្ជាប់ទំនាក់ទំនងឆ្លងដែន និងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅមូលដ្ឋានប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា។<br><br>១.២ ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គរួមគ្នាគ្រប់គ្រងធនធានធម្មជាតិក្នុងអាងទន្លេមេគង្គ ឱ្យកាន់តែប្រសើរជាងមុនដើម្បីគ្រប់គ្រងធនធានទឹកក្នុងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព។ | ២.១ កសិករខ្នាតតូច ទាំងស្ត្រី ទាំងបុរស នៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ជាពិសេសកសិករជនជាតិដើមភាគតិចអាចមានលទ្ធភាពទទួលបាន និងគ្រប់គ្រងដីកសិកម្ម និងធនធានព្រៃឈើបានជាប់លាប់ និងប្រកបដោយសមធម៌។<br><br>២.២ កសិករខ្នាតតូចទាំងស្ត្រីទាំងបុរសនៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាមប្រើប្រាស់ការអនុវត្តន៍ផ្នែកកសិកម្មដែលអាចធន់[៤] មួយនឹងការប្រែប្រួលអាកាសធាតុ និងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិផង និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារផង។ | ៣.១ ប្រទេសក្នុងតំបន់មេគង្គទទួលស្គាល់ និងគោរពសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ហើយពលករអាចទាមទារសិទ្ធិរបស់ពួកគេបាន។ |
| លទ្ធផលសម្រាប់ប្រទេសកម្ពុជា | ១.៣ ស្ត្រី និងបុរសដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះ ប្រើប្រាស់សេវាសាធារណៈដែលមានសមធម៌ និងការឆ្លើយតប (ផ្នែកសុខភាព អប់រំ ទឹក និងអនាម័យ)។<br><br>១.៤ ប្រជាពលរដ្ឋាពិសេសស្ត្រី និងក្រុមងាយរងគ្រោះអាចលើកឡើងពីតម្រូវការអនុវត្តសិទ្ធិរបស់ខ្លួន និងចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន។ | ២.៣ កសិករខ្នាតតូចទាំងស្ត្រីទាំងបុរស (រួមទាំងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងជនជាតិដើម ភាគតិចផង) បង្កើនភាពធន់នៃមុខរបរចិញ្ចឹមជីវិតរបស់ពួកគេទៅនឹងវិបត្តិនានាដែលអាចកើតមានឡើង។<br><br>២.៤ ស្ត្រី និងបុរសជាពិសេសអ្នកមកពីសហគមន៍ ជនជាតិដើមភាគតិចអាចបង្កបង្កើនផលបានកាន់តែច្រើនជាងមុន និងអាចទទួលបាន និងគ្រប់គ្រងធនធាន(ព្រៃឈើ និងនេសាទ) ក្នុងសហគមន៍របស់ពួកគេបានជាប់លាប់ និងប្រកបដោយសមធម៌។ | ៣.២ ស្ត្រី និងបុរសដែលបានចូលរួមនៅក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទទួលបានចំណូលច្រើនជាងមុនពីការងារសមរម្យដែលពួកគេទទួលបាន។<br><br>៣.៣ ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសក្របខ័ណ្ឌប្បញ្ញត្តិកម្ម និងប្រព័ន្ធផ្តល់ការអប់រំប្រភេទនេះត្រូវបានពង្រឹងដោយមានទិសដៅឆ្លើយតបទៅនឹងសមាហរណកម្មអាស៊ាន។ |

៤ ភាពធន់ គឺជាសមត្ថភាពរបស់បុគ្គលម្នាក់ គ្រួសារមួយ សហគមន៍មួយ ប្រទេសមួយ ឬតំបន់មួយដើម្បីទប់ទល់បន្ស៊ាំ និងធូរស្រាលឡើងវិញយ៉ាងឆាប់រហ័សពីភាពតានតឹង និងវិបត្តិនានា។

<table>
<tr>
<td rowspan="2">លទ្ធផលសម្រាប់ប្រទេសឡាវ</td>
<td>១.៥ ស្រ្តី និងបុរសឡាវ ដែលរស់នៅក្នុងស្រុកដែលក្រខ្សត់ជាងគេប្រើប្រាស់សេវាប្រកបដោយគុណភាពដែលពាក់ព័ន្ធទៅនឹងវិស័យនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដោយសារតែការផ្តល់សេវាសាធារណៈមានសមធម៌ប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។<br><br>១.៦ ប្រជាពលរដ្ឋជនជាតិឡាវ ទាំងស្រ្តីទាំងបុរសចូលរួមនៅក្នុងការជជែកវែកញែកជាសាធារណៈផ្អែកទៅតាមព័ត៌មានត្រឹមត្រូវដើម្បីរៀបចំនូវគោលនយោបាយដែលឆ្លើយតបទៅនឹងតម្រូវការទាំងអស់គ្នា និងដើម្បីទាមទារឱ្យរដ្ឋាភិបាលមានគណនេយ្យភាពចំពោះសកម្មភាពរបស់ខ្លួន។</td>
<td>២.៥ កសិករខ្នាតតូច ទាំងស្រ្តី ទាំងបុរស រាប់បញ្ចូលទាំងក្រុមជនជាតិដើមភាគតិចផងមានភាពធន់និងសន្តិសុខស្បៀងខ្ពស់ជាងមុន។<br><br>២.៦ កសិករខ្នាតតូច ទាំងស្រ្តី ទាំងបុរស រាប់បញ្ចូលទាំងក្រុមជនជាតិដើមភាគតិចផងអាចបង្កបង្កើនផលបានខ្ពស់ជាងមុនទទួលបានលក្ខខណ្ឌលក់ប្រសើរជាងមុន និងមានប្រាក់ចំណូលច្រើនជាងមុន។</td>
<td rowspan="2">៣.៤ ក្របខ័ណ្ឌប្បញ្ញត្តិកម្ម និងយន្តការអនុវត្តនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅក្នុងប្រទេសឡាវត្រូវបានតម្រង់ទិសទៅរកដំណើរការសមាហរណកម្មអាស៊ានបំពេញបានទៅតាមតម្រូវការទាំងបរិមាណ និងគុណភាពនៃទីផ្សារការងារ និងមានដាក់បញ្ចូលក្រុមជួបប្រទះការលំបាក។<br><br>៣.៥ ស្រ្តី និងបុរសដែលរស់នៅតាមតំបន់ជនបទជាពិសេសជនជាតិដើមភាគតិចអាចទទួលបានចំណូលខ្ពស់ជាងមុនដោយសារតែពួកគេមានជំនាញខ្ពស់ជាងមុនតាមរយៈការងារ និងការលក់ទំនិញ និងសេវាបានកាន់តែប្រសើរជាងមុន។</td>
</tr>
<tr>
<td colspan="2">១.៧ និង ២.៧ ស្រ្តី និងបុរសដែលរស់នៅតាមតំបន់ជនបទ រាប់បញ្ចូលទាំងជនជាតិដើមភាគតិចផងអាចទទួលបាន និងគ្រប់គ្រងលើដីកសិកម្ម និងធនធានព្រៃឈើបានជាប់លាប់ និងប្រកបដោយសមធម៌។</td>
</tr>
<tr>
<td>លទ្ធផលសម្រាប់ប្រទេសវៀតណាម</td>
<td>១.៨ ប្រជាពលរដ្ឋ ទាំងស្រ្តី ទាំងបុរស ដែលរស់នៅក្នុងខេត្តចំនួនបួន ( Hoa Binh, Cao Bang, Thai Nguyen, Quang Binh ) រៀបចំផែនការរៀបចំថវិកា អនុវត្ត និងពិនិត្យតាមដានការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចនៅក្នុងឃុំរបស់ខ្លួន។<br><br>១.៩ ប្រជាពលរដ្ឋ ទាំងស្រ្តី ទាំងបុរសទទួលបានប្រយោជន៍ពីការបំពេញការងាររបស់រដ្ឋបាលសាធារណៈដែលមានប្រសិទ្ធភាពមានភាពស័ក្តិសិទ្ធិ មានតម្លាភាព និងមានគណនេយ្យភាពជាងមុន។</td>
<td>២.៨ កសិករទាំងស្រ្តី ទាំងបុរស នៅតាមខេត្តមួយចំនួនអាចរកចំណូលបានច្រើនជាងមុនតាមរយៈការទទួលបានទីផ្សារកាន់តែមានប្រសិទ្ធភាពជាងមុន។<br><br>២.៩ កសិករទាំងស្រ្តីទាំងបុរសនៅតាមខេត្តមួយចំនួនប្រើប្រាស់សេវាពាក់ព័ន្ធនឹងកសិកម្ម និងការអភិវឌ្ឍន៍ជនបទដែលមានលក្ខណៈកាន់តែប្រសើរជាងមុន និងឆ្លើយតបចំពោះតម្រូវការរបស់ពួកគេ។</td>
<td>មិនទាន់បានចាប់ផ្តើមកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដោយសារតែការដកសកម្មភាពចេញបន្តិចម្តងៗ។</td>
</tr>
</table>

# ឧបសម្ព័ន្ធទី ២ ៖ ក្របខ័ណ្ឌលទ្ធផលរបស់ប្រទេសកម្ពុជាតាមវិស័យ

<table>
<tr><th colspan="3">គោលដៅនៃកម្មវិធីអភិបាលកិច្ចមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋនៅកម្ពុជា<br>យន្តការអភិបាលកិច្ចមូលដ្ឋានដែលមានភាពល្អប្រសើរជាងមុន ចូលរួមចំណែកលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍ប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា</th></tr>
<tr><th>(១) លទ្ធផលនៃសកម្មភាពការងាររបស់ស្វីស</th><th>(២) ការរួមចំណែករបស់កម្មវិធីស្វីស</th><th>(៣) លទ្ធផលនៃការអភិវឌ្ឍន៍សម្រាប់ប្រទេស</th></tr>
<tr>
<td>លទ្ធផល ១.៣<br>ស្ត្រី និងបុរសក្រីក្រ និងងាយរងគ្រោះប្រើប្រាស់សេវាសាធារណៈដែលមានសមធម៌ និងការឆ្លើយតប (ដូចជាសេវាសុខភាព អប់រំ ទឹកស្អាត និងអនាម័យ)<br>សូចនាករ៖<br>- ភាគរយនៃថវិកាជាតិដែលត្រូវបានវិភាជន៍(និងផ្ទេរ) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមការប្រគល់មុខងារឡើងវិញ។<br>- ភាគរយនៃប្រជាពលរដ្ឋនៅមូលដ្ឋាន (បែងចែកតាមភេទ ជាតិពន្ធុ និងពិការភាព)ដែលពេញចិត្តជាមួយនឹងគុណភាពនៃការផ្តល់សេវា(សុខភាព ការអប់រំបឋមសិក្សា ទឹកស្អាត និងអនាម័យ)<br>ទិន្នន័យគោល និងទិន្នន័យចំណុចដៅឆ្នាំ ២០១៧នឹងត្រូវកំណត់នៅក្នុងឆ្នាំ២០១៣។</td>
<td>និន្នាការ និងចលករនៃការផ្លាស់ប្តូរ<br>កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់ទូទាំង រដ្ឋាភិបាលក្នុងគោលបំណងកសាង និងពង្រឹងស្ថាប័នរដ្ឋឱ្យមានគណនេយ្យភាព និងលើកកម្ពស់សេវាសាធារណៈនៅកម្រិតវិមជ្ឈការ។ រដ្ឋបាល និងក្រុមប្រឹក្សាកម្រិតវិមជ្ឈការដែលត្រូវបានបង្កើតឡើងនៅថ្នាក់ឃុំ ស្រុក និងខេត្តផ្តល់នូវឱកាសដ៏សំខាន់មួយដើម្បីឱ្យមានការផ្តល់សេវាកាន់តែមានគុណភាពដល់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន។ បញ្ហាប្រឈមធំៗចំពោះមុខរួមមាន ៖ ការបញ្ជាក់ឱ្យបានច្បាស់ពីការប្រគល់មុខងារ ការបង្កើនការទទួលបានធនធានវិមជ្ឈការសារពើពន្ធ និងអ្វីដែលសំខាន់ជាងគេគឺ ការកសាងសមត្ថភាពនៅគ្រប់កម្រិតទាំងអស់។កម្មវិធីជាតិ១០ឆ្នាំ សំរាប់កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(២០១០-២០១៩) គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្រដ៏សំខាន់ និងជាកម្លាំងចលករជំរុញប្រទេសនេះ ដើម្បីធានាបាននូវស្ថិរភាពជាតិការផ្តល់សេវាកាន់តែប្រសើរជាងមុន និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។ ការប្តេជ្ញាចិត្តកម្រិតនយោបាយដើម្បីសម្រេចគោលដៅខាងលើនេះ ហើយមានមន្ត្រីពាក់ព័ន្ធរាប់ពាន់នាក់នៅទូទាំងប្រទេសកំពុងចូលរួមចំណែកនៅក្នុងកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩។<br>សម្មតិកម្មអំពីលទ្ធផលរយៈពេលវែង ៖<br>ជាមួយនឹងអណត្តិស្ថាប័ន ដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់ រួមជាមួយនឹងធនធានគ្រប់គ្រងបុគ្គលិកមានសមត្ថភាព និងយន្តការគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្ត ស្រុក និងឃុំ) កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនឹងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងការផ្តល់នូវសេវា (សុខភាព អប់រំ ទឹកស្អាត និងអនាម័យ) ប្រកបដោយសមធម៌ ប្រសិទ្ធភាព និងការឆ្លើយតប។<br>នៅកម្រិតគោលនយោបាយ SDC នឹងចូលរួមចំណែកក្នុងកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈកិច្ចសន្ទនាគោលនយោបាយ និងគាំទ្រដល់ការកសាងសមត្ថភាព</td>
<td>លទ្ធផល ១<br>កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ៖<br>ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រោមជាតិផ្អែកតាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ តម្លាភាព និងគណនេយ្យភាពត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍នៅមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ។<br>សូចនាករ ៖<br>- លិខិតូបករណ៍គតិយុត្តិ សម្រាប់គាំទ្រដល់ការអនុវត្តច្បាប់រៀបចំអង្គការត្រូវបានរៀបចំឡើងទាន់ពេលវេលា (អនុកម្មវិធី ១.១ នៃផអ៣)។<br>- ការប្រគល់មុខងារសារជាថ្មីដល់ស្រុកក្រុង និងឃុំសង្កាត់ត្រូវបានវិភាគ និងធ្វើតេស្តសាកល្បង (អនុកម្មវិធី ១.៣ នៃផអ៣)។<br>- រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពគ្រប់គ្រងធនធានមនុស្ស និងមុខងាររដ្ឋបាល ហើយឧបករណ៍នានាដែលចាំបាច់ត្រូវមានត្រូវបានដាក់ឱ្យអនុវត្ត (អនុកម្មវិធី ២.៣ នៃ ផអ៣)។<br>- ក្របខ័ណ្ឌគោលនយោបាយ សម្រាប់ជាយន្តការផ្តល់ហិរញ្ញប្បទាន ដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើង (អនុកម្មវិធី ៤ នៃផអ៣)។</td>
</tr>
</table>

| | | |
|---|---|---|
| | របស់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ជម្រុញឱ្យមានការពង្រឹងយន្តការផ្តល់សេវានៅថ្នាក់មូលដ្ឋានការបំពេញមុខងារដែលកំណត់ដោយច្បាប់ការកៀងគរធនធានសមត្ថភាព និងការផ្តល់សេវា ប្រកបដោយគណនេយ្យភាពដោយរដ្ឋបាល និងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។<br><br>**នៅកម្រិតប្រតិបត្តិការ** SDC នឹងផ្តោតការយកចិត្តទុកដាក់លើ (១) ការជម្រុញ ឱ្យមានការតាក់តែងគោលនយោបាយពីក្រោមឡើងលើការរៀបចំផែនការ និងការពិនិត្យ តាមដានតាមបែបចូលរួម (២) ការផ្តល់ព័ត៌មាន និងការអប់រំផ្សព្វផ្សាយប្រកបដោយអត្ថន័យអំពីគោលនយោបាយសាធារណៈ និងសេវានានានៅថ្នាក់មូលដ្ឋាន និង (៣) ការផ្តល់អំណាចដល់ស្ត្រី និងបុរសក៏ដូចជាសហគមន៍មូលដ្ឋាន ដើម្បីឱ្យពួកគេក្លាយជាតួអង្គ ដែលនាំឱ្យមានការផ្លាស់ប្តូរសំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។<br><br>**ហានិភ័យ និងឧបសគ្គ ៖**<br>- កង្វះការសហការ និងការសម្របសម្រួលគ្នា ក្នុងចំណោមក្រសួងសំខាន់ៗ (ក្រសួងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ) ដែលនាំឱ្យមានភាពយឺតយ៉ាវក្នុងការវិភាជន៍ថវិកា<br>- ការថយចុះនូវការគោរពសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយនៅក្នុងបរិបទនៃនិន្នាការខុសគ្នា រវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង<br>- កង្វះការផ្តល់ថវិកាពីដៃគូ ធ្វើឱ្យយឺតយ៉ាវដល់សន្ទុះនៃកំណែទម្រង់ កង្វះការសម្របសម្រួល និងការធ្វើសុខដុមនីយកម្មនាំឱ្យមានភាពមិនស៊ីសង្វាក់គ្នា ក្នុងអភិក្រមការងារ។ | |
| **លទ្ធផល ១.៤**<br>ប្រជាពលរដ្ឋជាពិសេសស្ត្រី និងក្រុមងាយរងគ្រោះ អាចលើកឡើងពីសេចក្តីត្រូវការរបស់ពួកគេអនុវត្តសិទ្ធិរបស់ពួកគេ និងចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន<br><br>**សូចនាករ ៖**<br>- ចំនួនស្ត្រី និងបុរស រួមទាំងក្រុមជួបប្រទះការលំបាកផងដែលចូលរួមចំណែកយ៉ាង សកម្មក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងការរៀបចំផែនការនៅថ្នាក់មូលដ្ឋាន<br>- ចំនួនរដ្ឋបាលមូលដ្ឋានដែលកំពុងរៀបចំថវិកាឆ្លើយតបទៅនឹងយេនឌ័រ មានការកើនឡើង ទិន្នន័យគោល និងទិន្នន័យចំណុចដៅឆ្នាំ ២០១៧ នឹងត្រូវកំណត់នៅក្នុងឆ្នាំ ២០១៣។ | **និន្នាការ និងចលករនៃការផ្លាស់ប្តូរ**<br>មូលដ្ឋានគ្រឹះសម្រាប់វប្បធម៌ប្រជាធិបតេយ្យ ត្រូវបានដាក់ចេញនៅក្នុងប្រទេសកម្ពុជា ជាមួយនឹងការបោះឆ្នោតឃុំសង្កាត់លើកទី ១ នៅក្នុងឆ្នាំ ២០០២។ ក្នុងអំឡុងមួយ ទសវត្សរ៍កន្លងទៅនេះ ក្រុមប្រឹក្សានៅថ្នាក់មូលដ្ឋានត្រូវបានបង្កើត ចេញជារូបរាង និងធ្វើស្ថាប័នីយកម្ម ហើយជំហានចាប់ផ្តើមនៃដំណើរការរៀបចំផែនការ និងការធ្វើសេចក្តី សម្រេចចិត្តតាមបែបចូលរួម។ កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិជាមួយនឹងការប្រើប្រាស់អភិក្រមគ្របដណ្តប់រួមបានផ្តល់នូវមូលដ្ឋានដើម្បីឱ្យមានការផ្លាស់ប្តូរក្នុងការឈានទៅពង្រឹងគណនេយ្យភាព។ នៅថ្នាក់មូលដ្ឋានលំហប្រជាធិបតេយ្យ សម្រាប់បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងបង្កើតឱ្យមានប្រព័ន្ធគណនេយ្យភាពកំពុងមានការរីកចំរើន ប៉ុន្តែការរីកចំរើននេះនៅមានភាពផុយស្រួយនៅឡើយ ហើយក៏អាចត្រឡប់មករកភាពដើមវិញយ៉ាងងាយដែរ។ ចំណេះដឹងនិងការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីអភិបាលកិច្ចមូលដ្ឋាន និងសិទ្ធិរបស់ខ្លួននៅមានកម្រិតរួមផ្សំនឹងមរតកដែលបន្សល់ដោយសារសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ (កង្វះភាពស៊ីសង្វាក់គ្នា និងការជឿទុកចិត្តគ្នាក្នុងសង្គមការបាត់បង់នូវប្រពៃណី ស្នាមរបួសផ្លូវចិត្ត និងការភ័យខ្លាច) ផងនោះអាចជាឧបសគ្គ ដល់ការប្រាស្រ័យទាក់ទងរវាងគ្នាដោយសេរី និងការចូលរួមប្រកបដោយ | **លទ្ធផល ២**<br>ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩៖<br><br>កម្មវិធីសាកល្បង ដែលលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានរៀបចំឡើង និងអនុវត្តជុំវិញសិទ្ធិរបស់ប្រជាពលរដ្ឋ និងការចូលរួមរបស់ប្រជាពលរដ្ឋ ៖ សេចក្តីណែនាំ និងនីតិវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានរៀបចំឡើង និងអនុវត្តសាកល្បង។ សេចក្តីណែនាំនេះត្រូវបានប្រកាសដាក់ឱ្យអនុវត្ត។<br><br>សូចនាករ ៖<br>- សមត្ថភាពគ្រប់គ្រងគោលនយោបាយ និងកម្មវិធីត្រូវបានបង្កើតឡើងពិនិត្យតាមដាន និងគ្រប់គ្រងចាត់ចែងប្រកបដោយ ប្រសិទ្ធភាព (អនុកម្មវិធី ១.២)<br>- រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពរៀបចំផែនការហើយឧបករណ៍ និងប្រព័ន្ធនានាដែលត្រូវបានរៀបចំឡើងសម្រាប់ការរៀបចំផែនការ |

| | | |
|---|---|---|
| | អត្ថន័យនៅក្នុងដំណើរការនៃកំណែទម្រង់នានា។ តែទោះជាយ៉ាងណាក៏ដោយក្រុមប្រឹក្សា និងរដ្ឋបាលមូលដ្ឋានហាក់បីដូចជាកាន់តែអាចបញ្ចេញសម្លេងបានច្រើនជាងមុនដូចជាធ្វើការទាមទារឱ្យមានការកំណត់បន្ទាត់គណនេយ្យភាព ឱ្យបានច្បាស់លាស់ជាងមុន និងស្នើសុំធនធាន និងសមត្ថភាពបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហា និងឆ្លើយតបទៅនឹង តម្រូវការនៅថ្នាក់មូលដ្ឋាន។<br><br>**សម្មតិកម្មអំពីលទ្ធផលរយៈពេលវែង ៖**<br><br>លំហប្រជាធិបតេយ្យ ការពង្រឹងប្រព័ន្ធគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ ការបង្កើនចំណេះដឹង និងការយល់ដឹងអំពីសិទ្ធិនិងការទទួលខុសត្រូវនឹងនាំឱ្យមានការកើនឡើងនូវការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងអភិបាលកិច្ចមូលដ្ឋានហើយចុងក្រោយ សិទ្ធិ និងសេចក្តីត្រូវការរបស់ពួកគេនឹងទទួលបានការឆ្លើយតបកាន់តែប្រសើរជាងមុន។ ការពង្រឹងប្រព័ន្ធគណនេយ្យភាពមូលដ្ឋាន និងការជម្រុញលើកទឹកចិត្តឱ្យមានការចូលរួមនៅថ្នាក់មូលដ្ឋានទាមទារឱ្យមានការប្រើប្រាស់អភិក្រមទ្វេទិស គឺពីលើចុះក្រោមផង និងពីក្រោមឡើងលើផង។<br><br>**នៅកម្រិតគោលនយោបាយ** SDC នឹងផ្តល់ការគាំទ្រដល់ដៃគូ/អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន (ក្នុងនោះរាប់បញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាលផង) និងអាជ្ញាធរមូលដ្ឋាន (ជាពិសេសក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុក) ដើម្បីទាមទារឱ្យមានការរៀបចំគោលនយោបាយ ឆ្លើយតបទៅនឹងយេនឌ័រ និងបង្កើតឱ្យមាននូវលំហស្ថាប័នសម្រាប់សហគមន៍ដែលក្នុងនោះអង្គការសង្គមស៊ីវិល និងសមាជិកក្រុមប្រឹក្សាមូលដ្ឋានមាន សមត្ថភាពប្រាស្រ័យទាក់ទងការងារជាមួយគ្នាប្រកបដោយលក្ខណៈស្ថាបនា។<br><br>**នៅកម្រិតប្រតិបត្តិការ** SDC នឹងផ្តោតការយកចិត្តទុកដាក់លើ (១) ការពង្រឹងសិទ្ធិរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន ជាពិសេសស្ត្រី កុមារ និងក្រុមងាយរងគ្រោះដទៃទៀត ដើម្បីឱ្យពួកគេអាចទទួលបានជំនួយផ្លូវច្បាប់កាន់តែប្រសើរជាងមុន និងអាចចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនយោបាយ និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនានា និង (២) ការចូលរួមចំណែកកសាងនូវវប្បធម៌នៃការជឿទុកចិត្តគ្នា និងការសន្ទនាគ្នារវាង ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋានដែលជាធាតុផ្សំដ៏សំខាន់មួយសម្រាប់កសាង ឡើងវិញនូវបណ្តាញសង្គម និងស្តារឡើងវិញនូវកោសិកាសង្គម ដែលត្រូវបានបំផ្លិចបំផ្លាញនៅក្នុងរបបខ្មែរក្រហម និងសង្គ្រាមស៊ីវិលដែលអូសបន្លាយជាយូរឆ្នាំមកនោះ។<br><br>**ហានិភ័យ និងឧបសគ្គ ៖**<br><br>- វិសមភាពយេនឌ័រ អាកប្បកិរិយាដែលត្រូវបានចាក់ឫសយ៉ាងជ្រៅនៅក្នុងវប្បធម៌ និងការយល់ឃើញចំពោះស្ត្រី បន្តរាំងមិនឱ្យស្ត្រីអាចចូលរួមយ៉ាងពេញលេញ ក្នុងការងារអភិបាលកិច្ចមូលដ្ឋានបាន។<br><br>- រដ្ឋបាលថ្នាក់ក្រោមជាតិ មានគណនេយ្យភាពចំពោះរដ្ឋាភិបាលថ្នាក់ជាតិជាងចំពោះប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន | ត្រូវបានប្រើប្រាស់ ដូចដែលរំពឹងទុក និងមានប្រសិទ្ធភាព (អនុកម្មវិធី ៥.២)<br><br>- រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបានធនធានហិរញ្ញវត្ថុបានច្រើនជាងមុនហើយធនធានទាំងនេះត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព (អនុកម្មវិធី ៤.១) |

**អន្តរាគមន៍ ៖**

- ចូលរួមចំណែក ក្នុងការអនុវត្តន៍កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈកិច្ចសន្ទនាគោលនយោបាយ ការផ្តល់ថវិកា និងជំនាញដោយមានការផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការកសាងសមត្ថភាពយន្តការតាមបែបចូលរួមវិមជ្ឈការសារពើពន្ធ និងការប្រគល់មុខងារ។
- ចូលរួមចំណែកកសាងសមត្ថភាពសមាជិកក្រុមប្រឹក្សាជាស្ត្រី និងសមាជិកក្រុមប្រឹក្សាស្រុក ដើម្បីធានាឱ្យពួកគេអាចបញ្ចេញសម្លេង នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងផ្តល់ការគាំទ្រដល់សកម្មភាពនានា ដែលពង្រឹងសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារស្រុក/ខេត្ត។
- លើកកម្ពស់ឱ្យមានវេទិកាពិគ្រោះយោបល់ក្នុងលក្ខណៈស្ថាប័នរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងស្ត្រី និងបុរស ដែលរួមចំណែកកសាងការជឿទុកចិត្តគ្នាភាពចុះសម្រុងគ្នាក្នុងសង្គម និងការព្យាបាល ស្នាមរបួសផ្លូវចិត្តដែលបន្សល់ពីអតីតកាល។
- ជម្រុញលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋដូចជា តាមរយៈការផ្តល់ការគាំទ្រដល់អង្គការសង្គមស៊ីវិល ដែលកំពុងផ្តល់ការអប់រំដល់ប្រជាពលរដ្ឋ និងបំផុសចលនាសង្គមជុំវិញបញ្ហាសិទ្ធិ (ដោយផ្តោតការយកចិត្ត ទុកដាក់ជាពិសេសលើលទ្ធភាពទទួលបានយុត្តិធម៌ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការបោះឆ្នោត និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ)។

**ធនធាន ភាពជាដៃគូជាយុទ្ធសាស្ត្រ ដែលគ្រោងនឹងបង្កើតឱ្យមាន ៖**

កញ្ចប់ហិរញ្ញវត្ថុ ៖ ប្រមាណជា ១៣លាន CHF សម្រាប់រយៈពេល ៥ឆ្នាំ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍៖ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ, SIDA, UNICEF, EU, GIZ, អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ, ទីភ្នាក់ងារឯកជនសម្រាប់ការសហការរួមគ្នា (PACT), វិទ្យាស្ថានបណ្តុះបណ្តាលអ្នកគ្រប់គ្រង (VBNK), អង្គការស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា (CORD), មូលនិធិអាស៊ី, (TAF) លេខាធិការដ្ឋាននៃគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (អង្គការសីលការ) គោលដៅនៃកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជាលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋតាមតំបន់ជនបទជាពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។

គោលដៅនៃកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជា
លើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋតាមតំបន់ជនបទ ជាពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារ

| (១) លទ្ធផលនៃសកម្មភាពការងាររបស់ស្វីស | (២) ការរួមចំណែករបស់កម្មវិធីស្វីស | (៣) លទ្ធផលនៃការអភិវឌ្ឍន៍សម្រាប់ប្រទេស[៥] |
| --- | --- | --- |
| លទ្ធផល ២.៣<br>កសិករខ្នាតតូច ទាំងស្ត្រីទាំងបុរស (រួមទាំងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងជនជាតិដើមភាគតិចផង) បង្កើនភាពធន់នៃមុខរបរចិញ្ចឹមជីវិតរបស់ពួកគេទៅនឹងវិបត្តិនានាដែលអាចកើតមានឡើង។<br>**សូចនាករ ៖**<br>- ភាគរយគ្រួសារដែលមានស្បៀងអាហារ ហូបចុកគ្រប់គ្រាន់ពេញមួយឆ្នាំមានការកើនឡើង (បែងចែកតួលេខគ្រួសារដែលមានស្ត្រីជាមេគ្រួសារ)<br>- ចំណូលជាមធ្យមរបស់គ្រួសារមានការកើនឡើង | **និន្នាការ និងចលករនៃការផ្លាស់ប្តូរ**<br>បើទោះបីជាម៉ាក្រូសេដ្ឋកិច្ចមានកំណើនលឿនយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋ កម្ពុជាប្រមាណជា ៨០% នៅបន្តរស់នៅតាមតំបន់ជនបទ និង៧០% ពឹងអាស្រ័យលើរបរកសិកម្ម និងធនធានធម្មជាតិ (ធនធាននេសាទ ព្រៃឈើ) សម្រាប់ចិញ្ចឹមជីវិត។ ប្រជាពលរដ្ឋក្រីក្រនៅកម្ពុជាប្រមាណជា ៩០% រស់នៅតាមតំបន់ជនបទហើយប្រជាពលរដ្ឋ ក្រីក្រជាច្រើននាក់កំពុងប្រឈមនឹងបញ្ហាអសន្តិសុខស្បៀងបញ្ហាសុខភាព និងភាពងាយរងគ្រោះចំពោះវិបត្តិខាងក្រៅគ្រប់ប្រភេទទាំងអស់ដូចជា គ្រោះមហន្តរាយធម្មជាតិ ដែលបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុជាដើម។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារងាយរងហានិភ័យជាងគេដោយហេតុថាមានស្ត្រីជាង ៦៥% នៅកម្ពុជាដែលប្រកបរបរជាកសិករដែលជាក្រុមងាយរងគ្រោះពិសេស។ កសិករខ្នាតតូចដែលពឹងអាស្រ័យតែលើការបង្កបង្កើនផលស្រូវងាយរងគ្រោះជាងគេចំពោះវិបត្តិនានា។ គោលនយោបាយជាតិផ្តល់ការគាំទ្រដល់ "ការធ្វើប្រពលវប្បកម្ម" (ជាពិសេសសម្រាប់ផលិតកម្មស្រូវក្នុងគោលបំណងធ្វើឱ្យប្រទេស | **លទ្ធផល ១**<br>ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ASSDP ២០០៩-២០១៣ ៖<br>បង្កើនផលិតភាព និងពិពិធភាពកសិកម្មតាមរយៈ ៖<br>- ការបង្កើន និងវិមជ្ឈការសមត្ថភាពនៃសេវាផ្សព្វផ្សាយកសិកម្ម<br>- ការប្រើប្រាស់វិធីសាស្ត្ររួមគ្នារវាងសាលារៀនស្រែកសិករ និងសាលារៀនទីផ្សារកសិករ<br>ការបង្កើនលទ្ធភាពទទួលបានទីផ្សារសម្រាប់កសិផល និងផលិតផលដែលផលិតដោយកសិករខ្នាតតូច និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ (តាមរយៈការបង្កើនការយល់ដឹងអំពីតម្រូវការទីផ្សារនៅមូលដ្ឋាន |

៥ សម្គាល់ ៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP ២០១៤-២០១៨) នឹងត្រូវរៀបចំរួចរាល់នៅក្នុងឆ្នាំ ២០១៤។ ក្របខ័ណ្ឌលទ្ធផលនេះនឹងត្រូវធ្វើបច្ចុប្បន្នកម្ម។ NSDP នឹងរួមចំណែកចំពោះលទ្ធផលអភិវឌ្ឍន៍ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មទាំងនេះ។

<table>
<tr>
<td>ទិន្នន័យគោល និងចំណុចដៅសម្រាប់ឆ្នាំ ២០១៧ នឹងត្រូវកំណត់ដោយតម្រឹមឱ្យស្របបំផុតតាមដែលអាចធ្វើបានជាមួយនឹងយន្តការពិនិត្យតាមដានថ្នាក់ជាតិ</td>
<td>កម្ពុជាក្លាយជាប្រទេសនាំចេញអង្ករ) និង“ពិពិធកម្ម” ផលិតកម្មកសិកម្ម។ គោលនយោបាយទាំងនេះក៏គាំទ្រឱ្យវិស័យឯកជនបំពេញតួនាទីកាន់តែសកម្មក្នុងការផ្តល់នូវធនធានកសិកម្មកាន់តែល្អប្រសើរជាងមុន និងជំនួយបច្ចេកទេសទៅតាមតម្រូវការទីផ្សារ។ ប៉ុន្តែការគាំទ្ររបស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ នៅតែផ្តោតការយកចិត្តទុកដាក់លើការបង្កើនផលិតកម្មស្រូវ។<br><br>សម្មតិកម្មអំពីផលរយៈពេលវែង ៖<br><br>ការធ្វើពិពិធកម្មផលិតកម្ម និងការធានាយ៉ាងណាឱ្យគ្រួសារក្រីក្រមានសន្តិសុខស្បៀងពេញមួយឆ្នាំ និងអាចបង្កើនប្រាក់ចំណូលគ្រួសាររបស់ខ្លួន គឺជាគន្លឹះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌ និងចីរភាព។<br><br>នៅកម្រិតគោលនយោបាយ SDC នឹងផ្តល់ការគាំទ្រដល់កិច្ចពិគ្រោះយោបល់គោលនយោបាយនៅថ្នាក់ជាតិ ជាមួយនឹងក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាអំពីយុទ្ធសាស្ត្រកំណើនប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើពិពិធកម្មផលិតកម្ម និងការអភិវឌ្ឍន៍ជំនាញ និងជម្រុញឱ្យមានការបង្កើនសុខដុមនីយកម្មក្នុងចំណោមអ្នកផ្តល់ជំនួយ។<br><br>នៅកម្រិតប្រតិបត្តិការ SDC នឹងផ្តោតការយកចិត្តទុកដាក់ជាក់លាក់លើគ្រួសារដែលមានស្ត្រីជាមេគ្រួសារ នៅតាមបណ្តាខេត្ត ដែលបានទទួលការ គាំទ្រតិចតួចពីអ្នកផ្តល់ជំនួយ។ SDC នឹងគាំទ្រឱ្យមានការធ្វើពិពិធកម្មដំណាំ និងការអភិវឌ្ឍន៍ជំនាញពាក់ព័ន្ធ, បង្កើនសមត្ថភាពរបស់កសិករខ្នាតតូចដើម្បីបន្សាំខ្លួន និងឆ្លើយតបទៅនឹងប្រែប្រួលអាកាសធាតុ និងផលិតនូវអតិរេក ដែលអាចលក់លើទីផ្សារបាន (គួបផ្សំជាមួយនឹងលទ្ធភាពទទួលបានទីផ្សារ)។ SDC នឹងផ្សារភ្ជាប់ការអភិវឌ្ឍន៍ជំនាញជាមួយនឹងអន្តរាគមន៍អប់រំបណ្តុះបណ្តាលវិជ្ជាជីវៈដែលគាំទ្រដល់ការបង្កើនលទ្ធភាពទទួលបានទីផ្សារសម្រាប់ផលិតផលដែលមានតម្លៃខ្ពស់ និងធានាយ៉ាងណាឱ្យកសិករទទួលបានព័ត៌មានទីផ្សារកាន់តែប្រសើរជាងមុន ក៏ដូចជាជំនាញ និងធាតុចូលល្អជាងមុនសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត។<br><br>ហានិភ័យ និងឧបសគ្គ ៖<br><br>- រដ្ឋាភិបាលនៅតែបន្តផ្តោតការយកចិត្តទុកដាក់លើការជម្រុញការនាំចេញអង្ករដែលនាំឱ្យខ្វះធនធានសម្រាប់ឱកាសនាំចេញកសិផលមិនមែនអង្ករដែលមានតម្លៃខ្ពស់ផ្សេងទៀត<br>- មានការចាប់អារម្មណ៍តិចតួចពីអ្នកផ្គត់ផ្គង់ធនធានកសិកម្មក្នុងការផ្គត់ផ្គង់ធនធានល្អជាងមុនដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កសិករខ្នាតតូច<br>- ទីផ្សារសម្បូរផលិតផលពីប្រទេសថៃ និងវៀតណាម<br>- អ្នកប្រើប្រាស់ក្នុងស្រុកបន្តចាត់ទុកកសិផលនាំចូលថាមានគុណភាពខ្ពស់ជាងកសិផលក្នុងស្រុក/កសិកផលក្នុងស្រុកមិនអាចប្រកួតប្រជែងជាមួយនឹងកសិកផលដែលនាំចូលបាន</td>
<td>និងលក្ខខណ្ឌនានា ក៏ដូចជារបបនៃការធ្វើពាណិជ្ជកម្មក្នុងពិភពលោក)។<br><br>សូចនាករ ៖<br>- សូចនាករភាពក្រីក្រពាក់ព័ន្ធនឹងស្បៀងអាហារ (ពោល គឺចំនួនប្រជាជនជួបប្រទះ នឹងបញ្ហាអសន្តិសុខស្បៀង ដូចដែលត្រូវបានពិនិត្យតាមដានជារៀងរាល់ឆ្នាំនៅក្នុង“ការអង្កេតសេដ្ឋកិច្ចកម្ពុជា”)។<br><br>ទិន្នន័យគោល ៖<br><br>ភាពក្រីក្រពាក់ព័ន្ធនឹងស្បៀងអាហារឆ្នាំ ២០១០ = ១៥%</td>
</tr>
<tr>
<td colspan="3">អន្តរាគមន៍ ៖<br><br>- មានគាំទ្រដល់ពិពិធកម្មផលិតកម្ម ការបង្កើនលទ្ធភាពទទួលបានទីផ្សារ និងការបង្កើនអាហារូបត្ថម្ភតាមរយៈគម្រោងសង្វាក់ផ្គត់ផ្គង់សម្រាប់ដំណាំមិនមែនស្រូវក្នុងគោលបំណងបង្កើនសន្តិសុខស្បៀង</td>
</tr>
</table>

- ការពង្រីក/អនុវត្តបន្តនូវការអនុវត្តន៍ល្អ ក្នុងការគាំទ្រដល់សកម្មភាពចិញ្ចឹមជីវិត និងការតម្រឹមទិសឱ្យស្របគ្នាជាមួយនឹងផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់។
- ការគាំទ្រដល់ភាពធន់នៃមុខរបរចិញ្ចឹមជីវិតដូចជា ការប្រើប្រាស់អនុផលព្រៃឈើ ដើម្បីបង្កើនសន្តិសុខស្បៀង និងសក្តានុពលក្នុងការរកចំណូល ហើយក្នុងពេលជាមួយគ្នាគាំទ្រដល់ជីវចម្រុះសម្រាប់ផ្តល់ប្រយោជន៍ដល់ក្រុមមិនសូវមានឱកាស ជាពិសេស ជនជាតិដើមភាគតិច ដែលរស់នៅក្នុងខេត្តនៅប៉ៃកញ្ញសាន។
- ការគាំទ្រដល់ការធានាលទ្ធភាពទទួលបានកម្មសិទ្ធិដីធ្លី ដោយធ្វើការងារដាក់បញ្ចូល នៅក្នុងកម្មវិធីនាពេលអនាគតតាមដែលអាចធ្វើទៅបានដោយរាប់បញ្ចូលទាំងការគាំទ្រ ដល់ការដោះមីនសម្រាប់គោលបំណងអភិវឌ្ឍន៍ផងដែរ។

**ដៃគូយុទ្ធសាស្ត្រ ៖ សហភាពអឺរ៉ុប (ផ្នែកព្រៃឈើ និងនេសាទ) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កញ្ចប់ថវិកា ៖ ប្រហែលជា ១២ លាន** CHF សម្រាប់រយៈពេល ៥ ឆ្នាំ

**ដៃគូសក្តានុពល ៖** អង្គការឃែរអន្តរជាតិ អង្គការ IDE កម្ពុជា, អង្គការពេទ្យសត្វគ្មានព្រំដែន (AVSF), អង្គការ GRET, កម្មវិធីផ្លោះប្តូរអនុផលព្រៃឈើ (NTFP-EP), អង្គការ WWF, មជ្ឈមណ្ឌលសម្រាប់ប្រជាពលរដ្ឋ និងព្រៃឈើ (RECOFT), អង្គការ FAO, អង្គការ Oxfam, អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក/អង្គការតាមសហគមន៍ដូចជា អង្គការ Hurredo, អង្គការអភិវឌ្ឍន៍កសិកម្ម ដាណឺម៉ាកប្រចាំអាស៊ី (ADDA), Agrisud, CEDAC, PADEK, SNV, អង្គការនារីខ្មែរ និងអង្គការជនពិការអន្តរជាតិ។

គោលដៅនៃកម្មវិធីមុខរបរនិងការងារ និងអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជាស្ត្រី និងបុរសវ័យក្មេងដែលរស់នៅតាមទីជនបទ ទទួលបានជំនាញវិជ្ជាជីវៈ និងបំណិនជីវិត ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចបង្កើនប្រាក់ចំណូលរបស់ពួកគេ

| **(១) លទ្ធផលនៃសកម្មភាពការងាររបស់ស្វីស** | **(២) ការរួមចំណែករបស់កម្មវិធីស្វីស** | **(៣) លទ្ធផលនៃការអភិវឌ្ឍន៍កម្រិតប្រទេស** |
|---|---|---|
| លទ្ធផល ៣.២<br>ស្ត្រី និងបុរស ដែលចូលរួមនៅក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទទួលបានចំណូលកាន់តែច្រើន ពីការងារសមរម្យដែលពួកគេទទួលបាន។<br>**សូចនាករ ៖**<br>- ភាគរយនៃអ្នកបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដែលមានការងារសមរម្យធ្វើ ៦ ខែក្រោយពេលបញ្ចប់ការបណ្តុះបណ្តាល<br>- ភាគរយនៃអ្នកបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈដែលបង្កើតរបរដោយខ្លួន និងទទួលបានចំណូលកាន់តែច្រើន<br>ទិន្នន័យគោល និងចំណុចដៅសម្រាប់ឆ្នាំ ២០១៧ នឹងត្រូវរៀបចំនៅក្នុងឆ្នាំ ២០១៣។ | **និន្នាការ និងចលករនៃការផ្លាស់ប្តូរ**<br>ជារៀងរាល់ឆ្នាំមានយុវជន និងស្ត្រី បុរសពុំមានជំនាញប្រមាណ ៣០០០០០នាក់ ចូលមកក្នុងកម្លាំងពលកម្ម ប៉ុន្តែការងារដែលបង្កើតឡើងដោយកំណើនសេដ្ឋកិច្ចបច្ចុប្បន្ននេះមិនអាចតាមទាន់ចំនួនយុវជនដែលស្វែងរកការងារធ្វើនោះទេ។ ប្រទេសកម្ពុជាទទួលរងផលប៉ះពាល់ដោយសារតែវិស័យសេដ្ឋកិច្ចសំខាន់ៗរបស់ខ្លួននៅមានផលិតភាពទាបបើធៀបជាមួយនឹងប្រទេសជា សមាជិកអាស៊ានដទៃទៀត ដែលកត្តានេះធ្វើឱ្យរាំងស្ទះដល់លទ្ធភាពរបស់ប្រទេសកម្ពុជាក្នុងការទាញប្រយោជន៍ពីសមាហរណកម្មថ្នាក់តំបន់។ បញ្ហាសំខាន់ពាក់ព័ន្ធជាមួយនឹងការអប់រំ និងការអភិវឌ្ឍជំនាញ គួបផ្សំនឹងស្ថាប័ន បណ្តុះបណ្តាលដែលមិនអាចឆ្លើយតបឱ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការទីផ្សារដែលនឹងមាននាពេលខាងមុខធ្វើឱ្យរាំងស្ទះដល់កំណើនសម្រាប់ទាំងអស់គ្នា។ ការរាំងស្ទះទាំងនេះ ធ្វើឱ្យប្រយោជន៍ ដែលទទួលបានពីកំណើនសេដ្ឋកិច្ចកន្លងមកប្រឈមនឹងហានិភ័យ រួមចំណែកធ្វើឱ្យកម្លាំងពលកម្មនៅ តែបន្តទទួលបានប្រាក់ឈ្នួលទាបរួមចំណែកធ្វើឱ្យមានការកេងប្រវ័ញ្ច ការរំលោភបំពាន កង្វះការការពារដល់សិទ្ធិពលករក្នុងកម្រិតខ្ពស់ និងបង្កើនការធ្វើចំណាកស្រុក (ពីតំបន់ជនបទ ទៅតំបន់ប្រជុំជន និងទៅក្រៅប្រទេស) ដែលនាំឱ្យមានការកើនឡើងនូវការមិនសប្បាយចិត្ត និងភាពតានតឹងក្នុងសង្គម។ ចលករដែលនាំឱ្យមានការផ្លាស់ប្តូររួមមាន i) យុវជនចង់បានការអភិវឌ្ឍជំនាញឱ្យបានកាន់តែប្រសើរជាងមុន ii) គំនិតផ្តួចផ្តើមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការបង្កើតនូវគំនិតផ្តួចផ្តើមគំរូ ដែលអាចពង្រីកបន្ថែមទៀត iii) តម្រូវការ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣៖<br>ការអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបន្តផ្តល់ការបណ្តុះបណ្តាលជំនាញផ្សេងៗ និងការបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រនៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ដល់មន្ត្រី និងប្រជាពលរដ្ឋទូទៅរួមនឹងជនជាតិដើមភាគតិចផង។<br>សម្គាល់ ៖ សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការងារ និងមុខរបរដោយមានកំណត់ពីគោលដៅ និងចំណុចដៅបែបបរិមាណនឹងត្រូវបានរៀបចំ ឡើងត្រឹមពាក់កណ្តាលឆ្នាំ ២០១៣ (ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ/ ធនាគារអភិវឌ្ឍន៍អាស៊ី)។<br>តួលេខតំណាងផ្អែកទៅតាមគោលបំណងដែលត្រូវបានដាក់ចេញនៅក្នុងគោលនយោបាយស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋាភិបាលដែលផ្តោតលើៈ<br>- ការពង្រីកសមត្ថភាពផ្គត់ផ្គង់ និងទិន្នផលរួម<br>- ការបញ្ចូលក្រុមដែលជួបប្រទះការលំបាក<br>- ការបង្កើនភាពពាក់ព័ន្ធ (វគ្គសិក្សាតាមតម្រូវការ, តាមទីផ្សារ)<br>- ក្របខ័ណ្ឌគុណវឌ្ឍិជាតិសម្រាប់បង្កើនការចូលរួមសមាហរណកម្ម ការទទួលបានចំណេះដឹង និងលទ្ធភាពរកការងារបានធ្វើ |

| | | |
|---|---|---|
| | របស់វិស័យឯកជន (វិស័យទេសចរណ៍ ឧស្សាហកម្ម) និងទីផ្សារក្នុងស្រុក (សម្រាប់កសិផលក្នុងស្រុក) iv) ផែនការកំណែទម្រង់គ្រប់ជ្រុងជ្រោយថ្មីដែលមានការសម្របសម្រួលរវាងក្រសួងនានាដែលទទួលខុសត្រូវ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់វិស័យឯកជន។<br><br>**សម្មតិកម្មអំពីផលរយៈពេលវែង ៖**<br><br>ការអភិវឌ្ឍន៍ជំនាញ នាំឱ្យមានឱកាសការងារកាន់តែប្រសើរជាងមុន ទទួលបានចំណូលកាន់តែខ្ពស់ជាងមុន និងចូលរួមចំណែកលើកកម្ពស់លក្ខខណ្ឌការងារ។ ជំនាញកាន់តែខ្ពស់ជាងមុន គឺជាគន្លឹះសម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារការងារ និងសម្រាប់ជួយឱ្យមានកំណើនបន្ថែមទៀត។ នៅក្នុងប្រទេសកម្ពុជា ការកែលំអការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈនឹងជួយដោះស្រាយដោយផ្ទាល់នូវហានិភ័យរបស់យុវជនគ្មានការងារធ្វើដែលអាចជួយកាត់បន្ថយនូវលទ្ធភាពកើតមានអំពើហិង្សា និងបទល្មើសនានា។<br><br>នៅកម្រិតគោលនយោបាយ SDC នឹងផ្តល់ការគាំទ្រដល់ក្រសួងទទួលខុសត្រូវដែលពាក់ព័ន្ធដើម្បីកែលំអប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជារួមក្នុងគោលបំណងបង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសដល់ស្ត្រី និងបុរសមានជីវភាពក្រីក្រដែលរស់នៅតាមតំបន់ជនបទ។<br><br>នៅកម្រិតប្រតិបត្តិការ SDC នឹង (១) ចូលរួមចំណែកពង្រីកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីបញ្ចូលជំនាញពាក់ព័ន្ធនឹងមុខរបរបន្ថែមទៀត (២) បង្កើនស្តង់ដារគុណភាពតាមរយៈការផ្តល់លិខិតបញ្ជាក់ក្រោមក្របខ័ណ្ឌគុណវឌ្ឍិជាតិដែលទើបនឹងបង្កើតកាលពីពេលថ្មីៗនេះ (ប្រក វិជ្ជាជីវៈ) (៣) ផ្សារភ្ជាប់ទំនាក់ទំនងរវាងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាមួយនឹងវិស័យដែលជាចលករនៃកំណើនសេដ្ឋកិច្ច (ដូចជាវិស័យទេសចរណ៍ និងកសិកម្មជាដើម) (៤) រួមចំណែកអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងបំណិនជីវិត និងការហ្វឹកហាត់កូនជាងសម្រាប់ស្ត្រី និងបុរសវ័យក្មេងដែលរស់នៅតាមតំបន់ជនបទ និងជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់មកប្រទេសកម្ពុជាវិញ និង(៥) បង្កើនលទ្ធភាពឱ្យយុវជន ដែលបញ្ចប់ការ បណ្តុះបណ្តាលជំនាញ និង/ឬជនទេសន្តរប្រវេសន៍ ដែលវិលត្រឡប់មកវិញឱ្យទទួលបានសេវាតម្រង់ទិសការងារ និងស្វែងរកការងារឱ្យធ្វើ។<br><br>**ហានិភ័យ និងឧបសគ្គ ៖**<br><br>- កង្វះការសម្របសម្រួលរវាងក្រសួងដែលទទួលខុសត្រូវ<br>- ភាពរាយប៉ាយនៃរបៀបធ្វើការងាររបស់អ្នកផ្តល់ជំនួយ | - ការប្រើប្រាស់ការបណ្តុះបណ្តាល និងការហ្វឹកហាត់កូនជាងតាមសហគ្រាស<br>- ការភ្ជាប់ទំនាក់ទំនង និងការស្វែងរកការងារឱ្យធ្វើតាមមជ្ឈមណ្ឌលការងារ<br>- ការបង្កើនសក្តានុពលរបស់ពលករ និប្រវេសន៍<br>- ការប្រើប្រាស់ពលករក្នុងស្រុកជំនួសឱ្យ ពលករបរទេស |
| **លទ្ធផល ៣.៣**<br><br>ពង្រឹងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ជាតិ ក្របខ័ណ្ឌប្បញ្ញត្តិកម្ម និងប្រព័ន្ធនៃការអនុវត្តក្នុងគោលដៅឈានឆ្ពោះទៅរកសមាហរណកម្មអាស៊ាន | **សម្មតិកម្មអំពីផលប៉ះពាល់ ៖**<br><br>ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាតម្រូវការបន្ទាន់មួយ ប្រសិនបើប្រទេសកម្ពុជាចង់នៅតែបន្តមានសមត្ថភាពប្រកួតប្រជែងនៅក្នុងបរិបទសមាហរណកម្មថ្នាក់តំបន់ និងដោះស្រាយបញ្ហាមិនស៊ីគ្នារវាងតម្រូវការក្នុងទីផ្សារ និងកម្លាំងពលកម្មជំនាញដែលមាន។ នៅកម្រិតគោលនយោបាយ SDC នឹងគាំទ្រដល់ក្រសួងការងារ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ កថាខណ្ឌ ៤៩៧ ៖<br><br>រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្ម ទៅនឹងលក្ខខណ្ឌ ការងារតាមរយៈការអនុវត្តប្រកបដោយ ប្រសិទ្ធភាពនូវ |

**សូចនាករ ៖**

- កំណែទម្រង់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកាន់តែមានភាពស៊ីជម្រៅ
- ចំនួនអ្នកទទួលបានការអប់រំបណ្តុះ បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានការ កើនឡើង (បែងចែកតាមភេទ និងខេត្ត)

ទិន្នន័យគោល និងចំណុចដៅសម្រាប់ឆ្នាំ ២០១៧ សម្រាប់សូចនាករទី ២ នឹងត្រូវកំណត់នៅក្នុងឆ្នាំ ២០១៣។

និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការតាក់តែងគោលនយោបាយថ្មីៗ ដោយផ្តោតជាពិសេសលើការផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់យុវជន និងយុវនារី ដែលមានជីវភាពក្រីក្រ និងមិនសូវមានឱកាស រួមទាំងពលករទេសន្តរប្រវេសន៍ ដែលមានសក្តានុពលផងដើម្បីធានា និងលើកកម្ពស់សិទ្ធិរបស់ពួកគេក្នុងការទទួលបានការងារសមរម្យធ្វើ និងការអនុវត្តន៍ស្តង់ដារការងារ។ SDC ក៏នឹងផ្តល់ការគាំទ្រដល់ការបង្កើតនូវស្តង់ដាគុណភាពជាតិផងដែរ។ លើសពីនេះ SDC នឹងផ្តល់ការចូលរួមចំណែក ធានាយ៉ាងណាឱ្យមានការដាក់បញ្ចូលសិទ្ធិការរបស់ពលករទេសន្តរប្រវេសន៍ទៅក្នុងយុទ្ធសាស្ត្រជាតិ។ នៅកម្រិតប្រតិបត្តិការ SDC នឹងចូលរួមចំណែក (១) ពង្រឹង និងបន្ថែមគុណតម្លៃដល់មជ្ឈមណ្ឌលការងារនៃទីភ្នាក់ងារជាតិការងារ និងមុខរបរ (២) គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការដាក់ ឱ្យអនុវត្តការផ្តល់ការណែនាំអំពីអាជីព (៣) គាំទ្រដល់ការអនុវត្តស្តង់ដារ នៅក្នុងក្របខ័ណ្ឌគុណវឌ្ឍិជាតិតាមរយៈការប្រើប្រាស់អភិក្រមពីក្រោមឡើងលើ (ដោយផ្តោតការយកចិត្តទុកដាក់លើសមត្ថភាព និងមុខរបរនៅកម្រិតទាប ដែលសមស្របសម្រាប់ប្រជាពលរដ្ឋនៅតំបន់ជនបទ) និង (៤) ការសម្រេចតាមចំណុចដៅពាក់ព័ន្ធច្បាប់ការងារ (ជំនាញបច្ចេកទេសជំនាញដោះស្រាយបញ្ហា និងភាសា, ឧបករណ៍សម្រាប់គាំទ្រដល់ការហ្វឹកហាត់កូនជាង និងឧបករណ៍/ដំណើរការសម្រាប់ធ្វើការពិនិត្យតាមដាន)។

**ហានិភ័យ ៖**

- ក្របខ័ណ្ឌគុណវឌ្ឍិជាតិ មិនទាន់បានចាប់ផ្តើម ឬពន្យារពេល
- មជ្ឈមណ្ឌលការងារ "សម្បូរដោយ" អតិថិជនថ្នាក់កណ្តាលដែលអាចបង់ថ្លៃបាន និងពុំអាចប្រើប្រាស់ ដោយប្រជាពលរដ្ឋក្រីក្រ

ស្តង់ដារការងារបទដ្ឋានពលកម្ម និងច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិនានារួមទាំងការបន្តជំរុញយន្តការ "រោងចក្រ ប្រសើរនៅកម្ពុជា" ការនាំចេញពលករទៅបរទេស ការពង្រឹងសមត្ថភាពជំនាញតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យសមស្របតាមតម្រូវការទីផ្សារដោយផ្តោតជាសំខាន់លើមុខសញ្ញាយុវជនដែលពុំមានលទ្ធភាពបន្តការសិក្សានៅសាលាចំណេះទូទៅ ជនពិការស្ត្រី ជនបាត់បង់ឱកាស និងជនជាតិភាគតិច ការកសាងប្រព័ន្ធស្ថិតិការងារ និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវ ព័ត៌មានស្តីពីតម្រូវការទីផ្សារការងារ ដើម្បីធានាឱ្យបាននូវចល័តភាពនៃពលកម្ម និងការពង្រឹងយន្តការដោះស្រាយវិវាទការងារដែលមានស្រាប់ដូចជា ក្រុមប្រឹក្សាអាជ្ញាកណ្តាល គណៈកម្មការដោះស្រាយបាតុកម្មកូដកម្មគ្រប់ថ្នាក់។

សម្គាល់ ៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) នឹងត្រូវបញ្ចប់នៅចុងឆ្នាំ ២០១៣។ ក្របខ័ណ្ឌលទ្ធផល សម្រាប់វិស័យនេះនឹងត្រូវរៀបចំឡើង។ SDC នឹងរួមចំណែក ចំពោះលទ្ធផលនៃការអភិវឌ្ឍន៍បច្ចុប្បន្នកម្មនេះ។

**អន្តរាគមន៍ ៖**

- ការគាំទ្រដល់កិច្ចពិគ្រោះយោបល់អំពីកំណែទម្រង់គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេស ការរៀបចំផែនការការបន្ទាប់

- ការអភិវឌ្ឍជំនាញបច្ចេកទេសប្រមូលផល និងការកែច្នៃចំណីអាហារ ដល់គ្រួសារក្រីក្រតាមជនបទ និងភ្ជាប់ទំនាក់ទំនងពួកគេ ជាមួយនឹងទីផ្សារក្នុងស្រុក ជាពិសេសជាមួយនឹងវិស័យទេសចរណ៍ ដែលកំពុងតែមានការរីកចម្រើនតាមរយៈការផ្តល់នូវការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលមានការទទួលស្គាល់ត្រឹមត្រូវ និងតាមរយៈ ការភ្ជាប់ទំនាក់ទំនងរវាងការផ្សព្វផ្សាយទីផ្សារ និងការលក់

- ពង្រឹងមជ្ឈមណ្ឌលការងារដែលទើបបង្កើតថ្មីរបស់ទីភ្នាក់ងារជាតិការងារ និងមុខរបរ តាមរយៈការពង្រីកការគ្របដណ្តប់ (ដល់ប្រជាពលរដ្ឋក្រីក្រ) ការពង្រីកសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ការបណ្តុះបណ្តាលមុនបម្រើការងារ និងមុនចេញដំណើរ ការវាយតម្លៃលើសមត្ថភាព) និងសេវាស្វែងរកការងារឱ្យធ្វើការភ្ជាប់ទំនាក់ ទំនងជាមួយនឹងគ្រឹះស្ថានបណ្តុះបណ្តាលថ្មីៗ។

- ផ្តួចផ្តើម និងគាំទ្រដល់ការហ្វឹកហាត់កូនជាង ដោយបញ្ចូលការអប់រំពីទ្រឹស្តី ជាមួយនឹងការអនុវត្តជាក់ស្តែងតាមសហគ្រាស ស្របទៅតាមច្បាប់ការងារ និងក្របខ័ណ្ឌគុណវឌ្ឍិជាតិ ដែលនឹងមានជាមួយនឹងមធ្យោបាយ ដើម្បីធានាឱ្យសហគ្រាសតូចៗ និងបេក្ខជនដែលមានជីវភាពក្រីក្រ អាចទទួលបានសេវានេះបាន។ គាំទ្រដល់ពលករនិប្រវេសន៍ (តាមរយៈការផ្តល់នូវជំនាញដោះស្រាយបញ្ហា) និងពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់មកវិញដើម្បីទាញប្រយោជន៍ពីបទពិសោធន៍ការងារ និងប្រាក់សន្សំដែលពួកគេយកពីបរទេសមក។

**ភាពជាដៃគូជាយុទ្ធសាស្ត្រ ៖ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទីភ្នាក់ងារជាតិការងារ និងមុខរបរ អង្គការអន្តរជាតិខាងការងារ** UNDP, ADB, SIDA។ កញ្ចប់ហិរញ្ញវត្ថុ ៖ ប្រមាណជា ៧ លាន CHF សម្រាប់ ៥ ឆ្នាំ។

ដៃគូសក្តានុពល ៖ Shift 360, HR INC, អង្គការដទៃទៀត នឹងត្រូវកំណត់។

# ឧបសម្ព័ន្ធទី ៣ ៖ ផែនការថវិកាជវិភាជន៍ថវិកាបែងចែកតាមប្រទេស និងវិស័យ

## ថវិកាវិភាជន៍ ដែលគ្រោងតាមប្រទេស (គិតជាលាន CHF)

| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | % ក្នុងឆ្នាំ ២០១៧ | % សរុប | សរុប |
|---|---|---|---|---|---|---|---|---|
| កម្ពុជា | ៨ | ៨,៥ | ១១,៥ | ១៣ | ១៤ | ៣២,៥% | ២៧% | ៥៥ |
| ឡាវ | ១៥,៥ | ១៧ | ១៨ | ១៨ | ១៨ | ៤២% | ៤២% | ៨៦,៥ |
| វៀតណាម | ៨,៥ | ៨ | ៤ | ២ | ០ | ០% | ១១% | ២២,៥ |
| តំបន់ | ៤ | ៥,៥ | ៦,៥ | ៧ | ៩ | ២១% | ១៥% | ៣២ |
| COOFs & SAM | ២ | ២ | ២ | ២ | ២ | ៤,៥% | ៥% | ១០ |
| សរុប | ៣៨ | ៤១ | ៤២ | ៤២ | ៤៣ | ១០០% | ១០០% | ២០៥ |

## ថវិកាវិភាជន៍ ដែលគ្រោងតាមវិស័យ

| វិស័យ | ២០១៣/១៧ គិតជា CHF | ២០១៣/១៧ គិតជា % |
|---|---|---|
| កសិកម្ម និងសន្តិសុខស្បៀង រួមទាំងការប្រែប្រួលអាកាសធាតុ | ៧០ | ៣៤% |
| អភិបាលកិច្ចមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋ | ៧០ | ៣៤% |
| ការងារ និងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣៣ | ១៦% |
| វិស័យផ្សេងទៀត (ជាពិសេស សុខាភិបាល) | ២២ | ១១% |
| COOFs & SAM | ១០ | ៥% |
| សរុប | ២០៥ | ១០០% |



# ឧបសម្ព័ន្ធទី ៤៖ ផែនទីប្រទេសកម្ពុជា

## រូបភាពទី ១៖ផែនទី និងអត្រានៃភាពក្រីក្រនៅតាមបណ្តា ខេត្តនានានៃប្រទេសកម្ពុជា ២០១១

ខេត្តនៅភាគខាងត្បូង និងអាគ្នេយ៍នៃប្រទេសកម្ពុជាដែលមានដង់ស៊ីតេប្រជាជនខ្ពស់ និងមានប្រពៃណីបង្កបង្កើនផលនៅនឹងកន្លែងជាយូរណាស់មកហើយ មានភាពក្រីក្រក្នុងអត្រាទាបជាងខេត្តដែល ស្ថិតនៅភាគខាងជើង ភាគឦសាន និងភាគពាយព្យ។




*ប្រភព ៖ NSDP ២០១៤-២០១៨*



**ការបោះពុម្ពផ្សាយ**

អ្នកកែសម្រួល ៖
ក្រសួងការបរទេសសហព័ន្ធ - FDFA
**ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ - SDC**
3003 Berne

រចនាដោយ ៖
ផ្នែករូបភាពរបស់ FDFA ទីក្រុង Bern

រូបថត ៖
Nathan Horton

ដើម្បីទទួលបានឯកសារនេះ ៖
sdc.admin.ch/publications

ទំនាក់ទំនងមកកាន់អ្នកឯកទេស ៖
ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ - SDC
អង្គភាពសហប្រតិបត្តិការថ្នាក់តំបន់
ផ្នែកអាស៊ីបូព៌ា
ទូរស័ព្ទ ៖ +៤១ ៥៨ ៤៦២ ៣៥ ១៧ ទូរសារ ៖ +៤១ ៥៨ ៤៦៥ ៩៣ ៥៧
www.sdc.admin.ch

ទីក្រុង Bern ខែ មករា ឆ្នាំ ២០១៤